**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សិក្ខាសាលា
# ស្តីពី
# ការចាប់ផ្តើមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍
# កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

ថ្ងៃទី៤និងទី៥ ខែធ្នូ ឆ្នាំ២០១៣

សណ្ឋាគារ ភ្នំពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា




រៀបចំដោយ៖ ក្រុមការងារគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន

ADB

# មាតិកា


១. សារតា ....................................................................................................៣
២. គោលបំណងសិក្ខាសាលា ....................................................................................................៤
៣. អ្នកចូលរួម ....................................................................................................៦
៤. លទ្ធផលសិក្ខាសាលា ....................................................................................................៦
៥. សន្និដ្ឋាននិងសំណូមពរ ....................................................................................................១១

ឧបសម្ព័ន្ធទី១៖ កម្មវិធីសិក្ខាសាលា
ឧបសម្ព័ន្ធទី២៖ តារាងឈ្មោះអ្នកអញ្ជើញចូលរួម
ឧបសម្ព័ន្ធទី៣៖ សន្ទរកថាបើក និងបិទរបស់ឯកឧត្តម ស៊ិន ខ័ណ្ឌី អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន
ឧបសម្ព័ន្ធទី៥៖ រូបថត
ឧបសម្ព័ន្ធទី៦៖ បទបង្ហាញរបស់វាគ្មិន

# ១. សាវតា

ដោយទទួលស្គាល់អំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ មកលើប្រទេសកម្ពុជា ប្រទេសយើងបានត្រូវជ្រើសរើសក្នុងចំណោមប្រទេសទាំង៩និងពីរតំបន់ ទូទាំងសកលលោកដើម្បីចូលរួមអនុវត្តកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ(PPCR) ក្រោមមូលនិធិវិនិយោគអាកាសធាតុ(CIF)។ គម្រោងនេះគឺដើម្បីសាកល្បង និងបង្ហាញពីវិធីបញ្ចូលការគិតគូរហានិភ័យនៃការប្រែប្រួលអាកាសធាតុនិងភាពធន់នឹងអាកាសធាតុចូលទៅក្នុងកម្មវិធី និងការរៀបចំផែនការអភិវឌ្ឍន៍ស្នូលមួយចំនួនជាមួយនឹងការចូលរួមចំណែកបន្ថែមទៅលើសកម្មភាពដទៃទៀត។ កម្មវិធីPPCR បានអនុវត្តរួមគ្នាដោយក្រុមធនាគារពិភពលោក (WBG) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

នៅប្រទេសកម្ពុជា យើងបានអនុវត្តកម្មវិធី PPCR នេះជាពីដំណាក់កាលគឺ ១) PPCR ដំណាក់កាលទី១ បានជួយគាំទ្រដល់ប្រទេសកម្ពុជាក្នុងការរៀបចំកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) ដែលរួមមានកម្មវិធីវិនិយោគពាក់ព័ន្ធមួយចំនួន។ ២)កម្មវិធី PPCR ដំណាក់កាលទី២ រួមមានការអនុវត្តនូវកម្មវិធីគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស និងគម្រោងវិនិយោគSPCR មួយចំនួនទៀត។ .

គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនេះ (TA 8179-CAM) គឺសម្រាប់បញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ បានចាប់ផ្តើមជាផ្លូវការនៅថ្ងៃទី២ខែកញ្ញាឆ្នាំ ២០១៣។ សកម្មភាពសំខាន់ៗរបស់កម្មវិធីនេះរួមមានឈ្មោះដូចខាងក្រោម៖

**<u>សមាសភាគទី១៖</u>** ពង្រឹង**ការសម្របសម្រួលកម្មវិធី SPCR និងការគាំទ្រសមត្ថភាពបច្ចេកទេស** សម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍
**<u>សមាសភាគទី២៖</u>** ធ្វើការ**សិក្សាពីលទ្ធភាពលំអិត** របស់គម្រោងមួយចំនួន ក្រោមកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA)
**<u>សមាសភាគទី៣៖</u>** បង្កើតយន្តការ**គាំទ្រសង្គមស៊ីវិល និងពង្រឹងសមត្ថភាព**ដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងប្រតិបត្តិការរបស់ខ្លួន នឹង
**<u>សមាសភាគទី៤៖</u>** ផលិត និង**ផ្សព្វផ្សាយឯកសារចំណេះដឹង**ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

អង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវជ្រើសរើសដើម្បីអនុវត្តសមាសភាគទី៣។ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន កំពុងអនុវត្តសមាសភាគទី១ ទី២ និងទី៤។ ក្រុមហ៊ុន ហាតហ្សៀល

(Hatfield) មកពីប្រទេសកាណាដា ផ្តល់ការគាំទ្របច្ចេកទេស ដោយសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងក្រុមហ៊ុន TANCONS នៅកម្ពុជា។

គោលបំណងរបស់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនេះ (TA) គឺត្រូវពង្រឹងសមត្ថភាពស្ថាប័ន និងអ្នកពាក់ព័ន្ធនៅកម្ពុជាក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍។ គម្រោងTAនេះ នឹងធ្វើការគាំទ្របច្ចេកទេសដល់ក្រុមសម្របសម្រួលនិងការអនុវត្តគម្រោងវិនិយោគទាំង៧របស់SPCR ដែលគម្រោងទាំង៧នេះផ្តោតទៅលើវិស័យកសិកម្ម ធនធានទឹក និងវិស័យហេដ្ឋារចនាសម្ព័ន្ធដែលមានថវិកាជិត៤០០លានដុល្លាអាមេរិក។ គម្រោងវិនិយោគទាំងនេះផ្តល់កាឡានុវត្តភាពដ៏សំខាន់មួយសម្រាប់ការកសាងភាពធន់នឹងអាកាសធាតុនៅកម្ពុជា និងដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយគ្រោះហានិភ័យទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍។ ដោយហេតុនេះ ការគាំទ្រដល់គម្រោងវិនិយោគទាំងនេះ គឺជាតួនាទីដ៏សំខាន់មួយក្នុងតួនាទីសំខាន់ៗដទៃទៀតរបស់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស។

ក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កាលពីថ្ងៃទី១៩ខែកញ្ញាឆ្នាំ២០១៣ ក៏បានរៀបចំ កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)នៅកម្ពុជា ដើម្បីប្រកាសចាប់ផ្តើមជាផ្លូវការរបស់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ សមាជិកសមាជិកានៃគណៈកម្មាធិការជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអញ្ជើញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ចំនួនប្រហែល ១៣០នាក់។

## ២. គោលបំណងនៃសិក្ខាសាលា

សិក្ខាសាលាស្តីពីការចាប់ផ្តើមកម្មវិធីជំនួយហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនេះរៀបចំឡើងដោយក្រសួងបរិស្ថាន( ទីភ្នាក់ងារប្រតិបត្តិរបស់TA ពីថ្ងៃទី៤និងទី៥ ខែធ្នូ ឆ្នាំ២០១៣ នៅសណ្ឋាគារភ្នំពេញ នៅរាជធានីភ្នំពេញ។ គោលបំណង និងលទ្ធផលរំពឹងទុករបស់សិក្ខាសាលារួមមាននៅក្នុងតារាងខាងក្រោមនេះ៖

*តារាង ១. គោលបំណង និងលទ្ធផលរំពឹងទុករបស់សិក្ខាសាលា*

| គោលបំណង | លទ្ធផលរំពឹងទុក |
|---|---|
| ១.ដើម្បីបង្ហាញជូន និងពិភាក្សាអំពីទិសដៅរួម វិធាន និងវិធីសាស្ត្ររបស់ TA សម្រាប់ធានាការអនុវត្តដោយជោគជ័យ ដើម្បីសម្រេចនូវលទ្ធផល និងផលសម្រេច និងសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជាដូចបានគ្រោងទុក | ទទួលបានគំនិតមតិស៊ីជម្រៅបន្ថែមទៀតក្នុងការធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្របសម្រួល SPCR និងសម្រាប់បញ្ចប់នូវរបាយការណ៍ចាប់ផ្តើមនេះ ផែនការអភិវឌ្ឍន៍សមត្ថភាព ផែនការ ព្រមទាំងទទួលបាននូវការឯកភាពគ្នាលើក្របខ័ណ្ឌតាមដានវាយតម្លៃផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ |
| ២.ដើម្បីបង្ហាញជូន និងឯកភាពគ្នាលើការស្វែងយល់ភាពប្រឈម និងសំណើដំណោះស្រាយដែលបានទទួលតាមរយៈការជួបពិភាក្សាជាមួយបណ្តាអ្នកពាក់ព័ន្ធនឹងការសិក្សាលើឯកសារនានានៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង | លទ្ធផលដំបូងនៃការចាប់ផ្តើមគម្រោងនិងដំណោះស្រាយត្រូវបានដាក់ក្នុងការជជែកវែកញែកនិងព្រមព្រៀងគ្នាទៅលើផែនការសកម្មភាពសម្រាប់កសាងសមត្ថភាពនិងលក្ខ័ណ្ឌនៃការអនុវត្តគម្រោងត្រូវបានកំណត់ |
| ៣.ដើម្បីបង្ហាញជូននិងពិភាក្សាលើផែនការសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធនិងផ្សព្វផ្សាយនិងទំនាក់ទំនង | ទទួលបានគំនិតស៊ីជម្រៅបន្ថែមទៀតនិងព្រមព្រៀងគ្នាក្នុងចំណោមអ្នកចូលរួមទៅលើយន្តការចូលរួមរបស់អ្នកពាក់ព័ន្ធនិងមធ្យោបាយដទៃទៀតសម្រាប់ការទំនាក់ទំនងមានប្រសិទ្ធភាព និងលើកឡើងនូវការផ្សព្វផ្សាយចំណេះដឹងដល់ក្រុមផ្សេងៗដែលពាក់ព័ន្ធ |
| ៤.ដើម្បីបង្ហាញជូន និងពិភាក្សាលើសេចក្តីត្រូវការកសាងសមត្ថភាពរបស់អ្នកសម្រេចចិត្ត មន្ត្រីជំនាញបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល (ការរៀបចំផែនការសកម្មភាពនិងថវិកា និងអនុវត្តសកម្មភាពនានាទាក់ទងទៅនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ | ទទួលបានគំនិតស៊ីជម្រៅបន្ថែមទៀតនិងព្រមព្រៀងគ្នាក្នុងចំណោមអ្នកចូលរួមទៅលើផែនការកសាងសមត្ថភាព មធ្យោបាយនិងវិធានផ្សេងៗដើម្បីដំណើរការឆ្ពោះទៅមុខក្នុងការអភិវឌ្ឍសមត្ថភាពបច្ចេកទេសស្ថាប័នដោយធ្វើសមាហរណកម្មវិធានការណ៍បន្សាំទៅក្នុងការអភិវឌ្ឍន៍របស់បុគ្គលិកបច្ចេកទេស និងអ្នកធ្វើសេចក្តីសម្រេចចិត្តនានា |
| ៥.ដើម្បីបង្ហាញជូននិងពិភាក្សាលើដំណើការសិក្សាលទ្ធភាពលំអិតលើគម្រោងមួយចំនួនក្រោមកម្មវិធី NAPA និងសមត្ថភាពបុគ្គលិករដ្ឋាភិបាលក្នុងការរៀបចំគម្រោងសំណើដាក់ជូនទៅមូលនិធិអន្តរជាតិដូចជាមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតងជាដើម | ឯកភាពគ្នាទៅលើដំណើរការធ្វើការសិក្សាលទ្ធភាពគម្រោង និងបង្កើតជាគម្រោងសំណើNAPA ដែលមានអាទិភាពខ្ពស់ និងស្វែងរកមធ្យោបាយដើម្បីកំណត់វិធីសាស្ត្ររបស់គម្រោង និងលទ្ធផលរំពឹងទុករបស់គម្រោងដែលអាចអនុវត្តបាននៅកន្លែងផ្សេងទៀត |

| | |
|---|---|
| ៦.ដើម្បីបង្ហាញជូននិងពិភាក្សាលើការអនុវត្ត ជំហានបន្ទាប់ដើម្បីធ្វើឲ្យប្រសើរឡើងនូវការ សម្របសម្រួល ចែកចាយ និងផ្លាស់ប្តូរ បទពិសោធន៍ទៅវិញទៅមកក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ | ទទួលលទ្ធផលល្អប្រសើរក្នុងការអនុវត្តជំហានបន្តបន្ទាប់ ដើម្បីការសម្របសម្រួល ផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ និងមានការត្រៀមលក្ខណៈល្អដើម្បីអនុវត្តគម្រោង ធ្វើរបាយការណ៍គម្រោងតាមរយៈចងក្រងរបាយការណ៍វឌ្ឍនភាពគម្រោង បង្កើតគេហទំព័រព័ត៌មាន ចងក្រងនិងផ្សព្វផ្សាយឯកសារចំណេះដឹង កិច្ចប្រជុំពិគ្រោះយោបល់ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ព្រមទាំងប្រព័ន្ធតាមដានវាយតម្លៃ និង ដំណើរការផែនការរំកិល។ |

## ៣. អ្នកចូលរួម

មានចំនួនអ្នកចូលរួមប្រហែលជាង១៩៣ នាក់ ដែលអញ្ជើញមកពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗ សមាជិក សមាជិកានៃគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ សមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ដៃគូអភិវឌ្ឍន៍នានា ក្រុមគម្រោងវិនិយោគSPCR ទាំង៧ អង្គការសង្គមស៊ីវិល សេវាឯកជន ក្រុមយុវជនពីគ្រឹះស្ថានអប់រំជាន់ខ្ពស់ និងសកលវិទ្យាល័យនានា នាយកដ្ឋានពាក់ព័ន្ធនានាក្នុងក្រសួងបរិស្ថាន ក្រុមគម្រោង SPCR និងសមាជិកបច្ចេកទេស TA។

## ៤. លទ្ធផលសិក្ខាសាលា

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមបានមានប្រសាសន៍ពីរចំនុចសំខាន់ៗដូចខាងក្រោម៖

- ភាពជាដៃគូជិតស្និទ្ធក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ(រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍)
- កម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសងាយរងគ្រោះខ្លាំងជាងគេ។ ការប្រែប្រួលអាកាសធាតុ នឹងកើនឡើងវិសាលភាពរបស់វា ដែលនាំអោយមានតម្រូវការកសាងសមត្ថភាពស្ថាប័ន និងជំនាញបច្ចេកទេសទាំងកម្រិតស្ថាប័ននិងកម្រិតមនុស្សម្នាក់ៗ

ជាមួយគ្នានេះ លោក Peter Brible នាយករងប្រចាំប្រទេស នៃធនាគារអភិវឌ្ឍន៍អាស៊ី នៅកម្ពុជាក៏មានប្រសាសន៍ថា៖

- ការខូចខាតកាលពីឆ្នាំកន្លងទៅៈ ជាង១៥០០លានដុល្លារសហរដ្ឋអាមេរិកដែលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា។
- កម្ពុជា ចូលរួមក្នុងការបញ្ចេញកាបូនតិចក្នុងបរិយាកាស ប៉ុន្តែទទួលរងផលប៉ះពាល់ខ្លាំងជាងប្រទេសដទៃទៀត ការប្រែប្រួលអាកាសធាតុ
- ការប្រែប្រួលអាកាសធាតុគឺជាអាទិភាពប្រតិបត្តិការ១ក្នុងចំណោម៥របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ថាមពល ទីក្រុងដែលមានបរិយាកាស និងការដឹកជញ្ជូនល្អ ការប្រើប្រាស់ដីដែលមានប្រសិទ្ធភាព និងការគ្រប់គ្រងព្រៃឈើ)។
- យុទ្ធសាស្រ្តក្នុងភាពជាដៃគូនៅកម្ពុជាគឺជាការចាំបាច់ ដែលការប្រែប្រួលអាកាសធាតុជាបញ្ហាអន្តរវិស័យ ហើយជាភាពប្រឈមដល់ការអភិវឌ្ឍជាតិ។
- វិធានចំបងគឺជាការចាំបាច់ វាត្រូវតែផ្តោតលើការគ្រប់គ្រងទឹកជំនន់តែប៉ុណ្ណោះទេ តែត្រូវផ្តោតលើ ការគ្រប់គ្រងធនធានទឹក ការបង្ហូរទឹក និងត្រូវធ្វើឲ្យមាននិរន្តរភាពផងដែរ។
- ការវិនិយោគភាពធន់នឹងអាកាសធាតុដោយជោគជ័យទាមទាឲ្យមានការប្រើប្រាស់ មធ្យោបាយនិងវិធីសាស្រ្តល្អៗ សម្រាប់ការកសាងភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវការសម្របសម្រួល និងអនុវត្តយ៉ាងជិតស្និទ្ធ។
- ការធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលតាមវិស្ស័យនិងអន្តរក្រសួងព្រមទាំងកែលម្អការអនុវត្តគម្រោងគឺជាការចាំបាច់។

បន្ទាប់មកតាងនាម **ឯកឧត្តមរដ្ឋមន្រ្តីក្រសួងបរិស្ថាន** និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ **ឯកឧត្តម ស៊ិន ខ័ណ្ឌី អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន** បានធ្វើសន្ទរកថាបើកអង្គសិក្ខាសាលា។ ឯកឧត្តម បានមានប្រសាសន៍យ៉ាងច្បាស់ថា ការកសាងភាពធន់នៅក្នុងវិស័យទាំង៣ជាអាទិភាព ដូចជាធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធក្រុង និងជនបទ និងចូលរួមចំណែកយ៉ាងសកម្មជាមួយប្រជាជនទូទៅក្នុងការកាត់បន្ថយការខូចខាតផ្នែកសេដ្ឋកិច្ច និងការខូចខាងផ្នែកសង្គម បរិស្ថាន និងវប្បធម៌របស់ជាតិ។

ឯកឧត្តម ស៊ិន ខ័ណ្ឌី ក៏បានបញ្ជាក់ផងដែរថា ការប្រែប្រួលអាកាសធាតុត្រូវបានទទួលស្គាល់ជាទូទៅ។ ការបង្កើននូវសមាសភាគឧស្ម័នក្នុងបរិយាកាសបានបង្កឲ្យមានកម្តៅផែនដីដែលជាផ្នែកមួយនៃការប្រែប្រួលអាកាសធាតុ។ តាមការព្យាករណ៍បានឱ្យដឹងថា កំដៅភពផែនដីនឹងកើនឡើងគួជាទីកត់សម្គាល់បើប្រៀបធៀបទៅនឹងកម្តៅផែនដីនៅចុងសត្សវត្សទី១៩។ ជាការពិតណាស់ ការប្រែប្រួលអាកាសធាតុនេះ

អាចនឹងជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច សង្គម បរិស្ថាន និងជីវៈចម្រុះ ទាំងនៅក្នុងប្រទេសអភិវឌ្ឍ ប្រទេសកំពុងអភិវឌ្ឍ ក៏ដូចជាប្រទេសអភិវឌ្ឍតិចតួច។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការងារប្រែប្រួលអាកាសធាតុជាបញ្ហាអាទិភាពមួយ ដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យយើងទាំងអស់គ្នា រួមគ្នាដោះស្រាយបញ្ហានេះ តាមរយៈការពង្រឹងសមត្ថភាពបន្សាំ ដើម្បីធានាបាននូវភាពធន់ទៅនឹងហានិភ័យនានា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។ ឯកឧត្តម ស៊ិន ខ័ណ្ឌី ក៏បានបញ្ជាក់ថា ជាមួយនេះផងដែរ កម្ពុជាផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើការពង្រឹងសមត្ថភាពស្ថាប័ន ក៏ដូចជាធនធានមនុស្សទាំងក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា។

ឯកឧត្តម ស៊ិន ខ័ណ្ឌី បានថ្លែងអំណរគុណដល់មូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានដល់កិច្ចដំណើរការនៃការអនុវត្តគម្រោងវិនិយោគទាំង៧ និងជំនួយសហប្រតិបត្តិការបច្ចេកទេស១នៅកម្ពុជា។

- **បទបង្ហាញទី១** ធ្វើឡើងដោយ បណ្ឌិត អានចា ស្រ៊ីនីវ៉ាសាន ប្រធានក្រុមការងារ និងអ្នកបច្ចេកទេសជាន់ខ្ពស់ ផ្នែកប្រែប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពី ការណែនាំ អំពីគោលបំណងគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ។
- **បទបង្ហាញទី២** ធ្វើឡើងដោយលោក អ៊ូ ច័ន្ទដារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី នៃក្រសួងបរិស្ថាន ស្តីពីវឌ្ឍនភាព សមិទ្ធផល និងបទពិសោធន៍សំខាន់ៗពី PPCR ដំណាក់កាលទី១ និងគោលបំណងសិក្ខាសាលា និងលទ្ធផលរំពឹងទុក។

**ក្រុមការងារគម្រោងTA ដែលមានអ្នកជំនាញជាតិចំនួន១០នាក់ និងអន្តរជាតិចំនួន៦នាក់ បានធ្វើបទបង្ហាញផ្សេងៗគ្នាទៅតាមប្រធានបទ និងជំនាញនីមួយៗ។**

- **បទបង្ហាញទី៣** ធ្វើឡើងដោយ លោកបណ្ឌិត ប៊ិច សុខេម ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ស្តីពីសេចក្តីព្រាងរបាយការណ៍ចាប់ផ្តើម និងផែនការការងារ។

- **បទបង្ហាញទី៤** ធ្វើឡើងដោយលោកបណ្ឌិត ហាមុត អ្នកជំនាញប្រែប្រួលអាកាសធាតុ និងប្រព័ន្ធស្រោចស្រព និង លោកបណ្ឌិត ស្កត កូនលីហ្វេ អ្នកជំនាញផ្នែកប្រែប្រួលអាកាសធាតុ និងហេដ្ឋារចនាសម្ព័ន្ធ និងកញ្ញា ទូស សោភ័ណ្ឌ ជំនាញយេនឌ័រ។ បទបង្ហាញនេះស្តីពីបេកគំហើញ ស្ថានភាពបច្ចុប្បន្ននៃចំណេះដឹងផលអន្តរាយទាំងឡាយដែលកើតឡើងដោយអាកាសធាតុ (កម្រិតសហគមន៍ ឬកម្រិតស្រុក) យុទ្ធសាស្ត្រ បទដ្ឋានច្បាប់នានា សមត្ថភាព និងក្របខ័ណ្ឌការងារស្ថាប័ន ការសិក្សាវាយតម្លៃដាក់លាក់ណាមួយ ឧបករណ៍ ត្រួតពិនិត្យហានិភ័យ និងគោលការណ៍ណែនាំផ្សេងៗ ការលើកឡើងពីវិធានជ្រុងបួនរបស់យើងក្នុងការបញ្ជ្រាប សកម្មភាព និងតម្រូវការការកសាងសមត្ថភាពទូទៅ និងវិធានយេនឌ័រក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។
- **បទបង្ហាញទី៥** ធ្វើឡើងដោយលោកបណ្ឌិត ដោក ដូម៉ា អ្នកជំនាញគ្រប់គ្រងកម្មវិធី និង លោក ធ័ម ប៊ូរីន អ្នកជំនាញអន្តរជាតិគ្រប់គ្រងចំណេះដឹងនិងទំនាក់ទំនង។ បទបង្ហាញនេះស្តីពីការងារសម្របសម្រួល SPCR និងការងារគាំទ្របច្ចេកទេសទៅកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងជនបង្គោលប្រែប្រួលអាកាសធាតុពាក់ព័ន្ធតាមស្ថាប័ន។
- **បទបង្ហាញទី៦** ធ្វើឡើងដោយកញ្ញា ទូស សោភ័ណ្ឌ អ្នកជំនាញយេនឌ័រ លោក សួន សេន និង កញ្ញា ប៉ូឡា ស៊ីលវ៉ា អ្នកជំនាញត្រួតពិនិត្យ និងវាយតម្លៃ។ បទបង្ហាញនេះស្តីពីការពិនិត្យតាមដានស៊ីជម្រៅផ្នែកយេនឌ័រ និងការវាយតម្លៃគម្រោង វិនិយោគ SPCR និង សមត្ថភាពអ្នកធ្វើសេចក្តីសម្រេចផ្នែកគោលនយោបាយ ព្រមទាំងសង្គមស៊ីវិល។
- **បទបង្ហាញទី៧** ធ្វើឡើងដោយលោកបណ្ឌិត ដោក ដូម៉ា អ្នកជំនាញគ្រប់គ្រងកម្មវិធី ស្តីពីចំណុច

  សំខាន់ៗ និងភាពប្រឈមសម្រាប់ស្ថាប័នមួយដែលមានសមត្ថភាពបច្ចេកទេស និងនិរន្តរភាពក្នុងធ្វើសមាហរណកម្មបន្សាំទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ដើម្បីលើកស្ទួយនូវភាពធន់នឹងអាកាសធាតុក្នុងកម្មវិធី ផែនការ និងគោលនយោបាយនានាតាមរយៈការកសាងសមត្ថភាពស្ថាប័នក្នុងការធ្វើផែនការសកម្មភាព និងផែនការថវិកា និងការអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុ និងដំណោះស្រាយ។
- **បទបង្ហាញទី៨** ធ្វើឡើងដោយលោកលោកបណ្ឌិត ឡាយ ចន្ធី លោកបណ្ឌិត ចែម ផល្លា និង លោកបណ្ឌិត ភិត ធ័រ ម៉ាណាមី ។ បទបង្ហាញនេះស្តីពីការសិក្សាលទ្ធភាពគម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (National Adaptation Programme of Action to Climate Change: NAPA)។

- **បទបង្ហាញទី៩** ធ្វើឡើងដោយលោក ហែម ចាន់ធូ មន្ត្រីជាន់ខ្ពស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីលទ្ធផលទី៣នៃយន្តការចូលរួមរបស់សង្គមស៊ីវិល។
- **បទបង្ហាញទី១០** ធ្វើឡើងដោយលោកស្រី យូ ប៉ោនី និង លោក ធ័ម ប៊ូរីន អ្នកជំនាញផ្នែកគ្រប់គ្រងចំណេះដឹង និងទំនាក់ទំនង លោក វ៉ាន់ សុខជា អ្នកជំនាញព័ត៌មាន និងផ្សព្វផ្សាយ លោក ហេង បូរ៉ាន់ អ្នកជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ស្តីពីផែនការគៀងគរអ្នកពាក់ព័ន្ធនិងផែនការទំនាក់ទំនង៖
  - របកគំហើញសំខាន់ៗ និងភាពប្រឈម
  - លើកផែនការសកម្មភាពទំនាក់ទំនង និងផែនការគៀងគរអ្នកពាក់ព័ន្ធ
- **បទបង្ហាញទី១១** ធ្វើឡើងដោយ លោកបណ្ឌិត ប៊ិច សុខេម ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងការសរុបលទ្ធផលសិក្ខាសាលាទាំងពីរថ្ងៃ។

## លទ្ធផលគន្លឹះៗសម្រេចបានរបស់សិក្ខាសាលានេះមានដូចតទៅ៖

- អ្នកចូលរួមបានយល់ច្បាស់ពីផែនសកម្មភាពការងារគម្រោងដំណាក់កាលទី២នេះជាពិសេសការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។
- ក្រុមការងារប្រមូលបាននូវបទពិសោធន៍ មតិយោបល់ ទស្សនៈវិស័យ ដើម្បីឈានទៅដល់ការកែសម្រួលរបាយការណ៍ចាប់ផ្តើម និងផែនការសកម្មភាពការងារដែលមានប្រសិទ្ធភាព ។
- ផែនការកសាងសមត្ថភាពនិងផែនការគ្រប់គ្រងចំណេះដឹងនឹងត្រូវលម្អិតថែមទៀតក្នុងរបាយការណ៍ចាប់ផ្តើមនេះដើម្បីធ្វើការបំពេញបន្ថែមទៅនឹងសកម្មភាពខ្វះចន្លោះរបស់ផែនការសកម្មភាពរបស់អ្នកពាក់ព័ន្ធដែលធ្វើការងារប្រែប្រួលអាកាសធាតុ។
- អ្នកចូលរួមបានផ្តល់ព័ត៌មានសម្រាប់ធ្វើការសិក្សាលម្អិតទៅគម្រោងពាក់ព័ន្ធ NAPA និងសកម្មភាពបន្សាំ។
- ក្រុមការងារនឹងប្រើប្រាស់ឧបករណ៍នឯកសារដែលមានស្រាប់ក្នុងក្របខ័ណ្ឌ PPCR1 CCCA NGOs និង ផែនការសកម្មភាពប្រែប្រួលអាកាសធាតុដទៃទៀត ។
- ក្រុមការងារត្រូវគិតគូរពីផែនការចូលរួមរបស់យេនឌ័រឲ្យបានលម្អិតថែមទៀតនៅក្នុងរបាយការណ៍ចាប់ផ្តើមនេះ។
- ក្រុមការងារគម្រោងនឹងផ្សារភ្ជាប់ការងារគម្រោងនេះជាមួយគម្រោងផែនការរបស់សម្ព័ន្ធភាពគ្រប់គ្រប់ការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

- របាយការណ៍ចាប់ផ្តើមនេះមានលក្ខណៈល្អប្រសើរ ប៉ុន្តែត្រូវការបង្ហាញពីពេលវេលាសកម្មភាពជាក់លាក់និងគួរតែបង្កើតយន្តការគ្រប់គ្រងចំណេះដឹងនិងយន្តការផ្សព្វផ្សាយចំណេះដឹងមានប្រសិទ្ធិភាព ជាពិសេសការបង្កើតគេហទំព័រផ្សព្វផ្សាយត្រូវមានព័ត៌មានដាក់ឲ្យអ្នកអានអាចទទួលបានព័ត៌មានគ្រប់គ្រាន់
- សហការជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុគឺជាដំណោះស្រាយចំបង។
- អ្នកចូលរួមជាពិសេសតំណាងតាមក្រសួងពាក់ព័ន្ធត្រៀមលក្ខណៈសម្របសម្រួលការងារជាមួយគម្រោងនៅពេលដែលក្រុមការងារសម្របសម្រួលត្រូវបានបង្កើតឡើង។

## ៥. សន្និដ្ឋាន និងសំណូមពរ

អង្គសិក្ខាសាលា ទទួលបានជោគជ័យ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ អ្នកពាក់ព័ន្ធទាំងអស់បានយល់ដឹងនូវគំនិតថ្មីៗ និងដោះដូរបទពិសោធន៍ល្អៗស្តីពីការបន្សាំនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅក្នុងបទសន្ទរកថាបិទអង្គសិក្ខាសាលា តាងនាម **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ឯកឧត្តម ស៊ិន ខ័ណ្ឌី អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន** បានជម្រាបថ្លែងអំណរគុណដោយស្មោះអស់ពីដួងចិត្តដល់សមាជិកសមាជិកានៃអង្គសិក្ខាសាលាទាំងមូល ដែលបានចូលរួមសិក្ខាសាលាយ៉ាងសកម្មរយៈពេលពីរថ្ងៃកន្លងមកនេះ ញុំាងអោយសម្រេចបាននូវលទ្ធផល ជាផ្លែផ្កាគួរជាទីមោទនៈ។ រាល់អនុសាសន៍ប្រកបដោយខ្លឹមសារសំខាន់ៗដែលយើងបានទទួលពីសិក្ខាសាលានេះ គឺជាត្រីវិស័យតម្រង់ទិស និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការអនុវត្តកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នាពេលខាងមុខ។ ខ្ញុំសូមថ្លែងការកោតសសើរចំពោះការខិតខំប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រុមការងារគម្រោង ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំសិក្ខាសាលាស្តីពីការបញ្ជ្រាបភាពធន់អាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នេះប្រកបដោយជោគជ័យ។ **ឯកឧត្តម ស៊ិន ខ័ណ្ឌី** បានគូសបញ្ជាក់គួជាទីកត់សម្គាល់ថា ភាពមិនប្រក្រតីនៃទឹកជំនន់ធំនៅឆ្នាំ២០០០ ស្ពានមួយចំនួននៅតាមដងផ្លូវជាតិលេខ៦A បានត្រូវកាត់ផ្តាច់ដោយសារទឹកជំនន់។ ដោយមានជំនួយពីប្រទេសជប៉ុន ស្ពានទាំងអស់នោះ បានកសាងឡើងវិញ ដោយបានគិតគូរពីភាពធន់នឹងទឹកជំនន់ ដែលនៅគង់វង្សរហូតដល់សព្វថ្ងៃ ថ្វីបើមានទឹកជំនន់ធំនៅឆ្នាំ២០១១ និង២០១៣ នេះ។

ការប្រែប្រួលអាកាសធាតុ នាំមកនូវហានិភ័យ និងកាលានុវត្តភាព សម្រាប់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ។ កត្តានេះ ញុំាងអោយឃើញអំពីតួនាទីដ៏សំខាន់របស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធអោយបានយូរអង្វែង។

ប្រសិនបើវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ជោគជ័យក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឱកាសនឹងកើនឡើងសម្រាប់ជានាផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម រួមគ្នានឹងការការពារប្រកបដោយប្រសិទ្ធភាពពីផលប៉ះពាល់មកពីការប្រែប្រួលអាកាសធាតុ។

តាងនាម **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ឯកឧត្តម ស៊ិន ខ័ណ្ឌី** ឆ្លៀតឱកាសនេះ សំណូមពរឲ្យតំណាងក្រសួងស្ថាប័ន ដែលក្រសួងបរិស្ថានបានចាត់លិខិតអញ្ជើញតែងតាំងមន្ត្រីសំខាន់ៗដើម្បីចូលរួមក្នុងក្រុមការងារអន្តរក្រសួង សម្រាប់សម្របសម្រួល SPCR សូមមេត្តាជួយតាមជម្រុញឲ្យមានការចាត់តាំងបញ្ជូនមន្ត្រីជាន់ខ្ពស់ និងនាយកគម្រោងវិនិយោគSPCRមកក្រសួងបរិស្ថានឲ្យបានឆាប់តាមការគួរ។ សូមមេត្តាបញ្ជូនយោបល់ និងអនុសាសន៍សម្រាប់ការកែសម្រួលសេចក្តីព្រាងរបាយការណ៍ចាប់ផ្តើម និងផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ និងផែនការកសាងសមត្ថភាពបានមុនថ្ងៃ២៥ ធ្នូ ២០១៣។

ឧបសម្ព័ន្ធទី១៖ កម្មវិធីសិក្ខាសាលា

# របៀបវារៈនៃសិក្ខាសាលា

# ស្តីពី

# ការចាប់ផ្តើមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

**Mainstreaming Climate Resilience into Development Planning (MCRDP)**

## ចាប់ពី ថ្ងៃទី០៤ ដល់ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣

## នៅសណ្ឋាគារ ភ្នំពេញ រាជធានីភ្នំពេញ

| **វេលា** | **ប្រធានបទ** | **អ្នកទទួលខុសត្រូវ** | **ប្រធានដឹកនាំ** |
|---|---|---|---|
| **ថ្ងៃទី១៖ ថ្ងៃពុធ ទី០៤ ខែធ្នូ ឆ្នាំ២០១៣** | | | |
| ០៧៖៣០-៨៖២០ | • ចុះឈ្មោះអ្នកចូលរួម | | |
| **ផ្នែកទី១៖ ពិធីបើកអង្គសិក្ខាសាលា** | | | |
| ០៨៖២០-០៨៖៣០ | • ពិធីប្រកាសគណៈអធិបតី ភ្ញៀវកិត្តិយស និងគោរពភ្លេងជាតិ | អ្នកស្រី យូ ប៉ោនី | |
| ០៨៖៣០-០៨៖៤០ | • សន្ទរកថាចំណាប់អារម្មណ៍ | ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| ០៨៖៤០-០៨៖៥០ | • សន្ទរកថាចំណាប់អារម្មណ៍ | លោក **តឺធើ ប្រ៊ឹមម៉ល** នាយករងធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា | |
| ០៨៖៥០-០៩៖១០ | • សន្ទរកថាបើកសិក្ខាសាលា | ឯកឧត្តម ស៊ិន ខ័ណ្ឌី អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | |
| ០៩៖១០-៩៖៤០ | • ពិធីថតរូបរួមគ្នា និងពិសារអាហារសម្រន់ | | |

| | | | |
|---|---|---|---|
| **ផ្នែកទី២៖ អំពីគោលបំណងជំនួយហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស វិធាន និងវិធីសាស្ត្រការអនុវត្តឱ្យបានជោគជ័យ ដើម្បីទទួលបាននូវលទ្ធផលរំពឹងទុករយៈពេលខ្លី និងរយៈពេលវែង** | | | |
| ០៩៖៤០-១០៖០០ | • ការណែនាំ អំពីគោលបំណងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ | • បណ្ឌិត អានចា ស្រ៊ីនីវ៉ាសាន ប្រធានក្រុមការងារ និងអ្នកបច្ចេកទេសជាន់ខ្ពស់ ផ្នែកប្រែប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ី | លោកបណ្ឌិត ទិន ពន្លក អគ្គនាយករង នៃ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន |
| ១០៖០០-១០៖២០ | • បទបង្ហាញសង្ខេប ស្តីពីវឌ្ឍនភាព សមិទ្ធផល និងបទពិសោធន៍សំខាន់ៗក្នុង PPCR ដំណាក់កាលទី១ និងគោលបំណងសិក្ខាសាលា និងលទ្ធផលរំពឹងទុក | • លោក អ៊ូ ច័ន្ទធារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី MCRDP នៃក្រសួងបរិស្ថាន | |
| ១០៖២០-១០៖៤០ | **សេចក្តីព្រាងរបាយការណ៍ចាប់ផ្តើម និងផែនការការងារ៖**<br>• គោលបំណង និងវិសាលភាពការងារ<br>• ការទទួលខុសត្រូវអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស<br>• របកគំហើញទូទៅ និងសកម្មភាពដំណាក់កាលនៃការចាប់ផ្តើម<br>• ការកសាងក្រុមការងារ<br>• កិច្ចការសង្ខេប និងលទ្ធផល ដែលត្រូវសម្រេចបានសម្រាប់ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស | • លោកបណ្ឌិត ប៉ិច សុខេម ប្រធានក្រុម និងជាអ្នកជំនាញប្រែប្រួលអាកាសធាតុនិងទឹក | បណ្ឌិត អានចា ស្រ៊ីនីវ៉ាសាន ប្រធានក្រុមការងារ និងអ្នកបច្ចេកទេសជាន់ខ្ពស់ ផ្នែកប្រែប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ី |
| ១០៖៤០-១១៖៣០ | • ការពិភាក្សារួម | • ប្រធានសម្របសម្រួល និង<br>• អ្នកចូលរួមទាំងអស់ | លោកបណ្ឌិត ប៉ិច សុខេម ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| ១១៖៣០-១២៖១៥ | • របាយការណ៍តាមក្រុម | | |
| ១១៖១៥-១៣៖៣០ | • សម្រាកពិសារអាហារថ្ងៃត្រង់ | | |
| **ផ្នែកទី៣៖ លទ្ធផលទី១៖ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍** | | | |
| ១៣៖៣០-១៤៖០០ | **ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ៖**<br>• របកគំហើញ ស្តីពីស្ថានភាពបច្ចុប្បន្ននៃចំណេះដឹងផលអន្តរាយទាំងឡាយដែលកើតឡើងដោយអាកាសធាតុ (កម្រិតសហគមន៍ ឬកម្រិតស្រុក) និងយុទ្ធសាស្ត្រ បទដ្ឋានច្បាប់នានា សមត្ថភាពនិងក្របខ័ណ្ឌការងារស្ថាប័ន ការសិក្សា | • លោកបណ្ឌិត ហាមុត អ្នកជំនាញប្រែប្រួលអាកាសធាតុ និងប្រព័ន្ធស្រោចស្រព និង<br>• លោកបណ្ឌិត ស្កុត កូនលីហ្វេ អ្នក | |

| | | | |
|---|---|---|---|
| | វាយតម្លៃដាក់លាក់ណាមួយ ឧបករណ៍ ត្រួតពិនិត្យហានីភ័យ និងគោលការណ៍ណែនាំផ្សេងៗ និង<br>• ការលើកឡើងពីវិធានផ្លុងប្អូនរបស់យើងក្នុងការបញ្ជ្រាប និង<br>• សកម្មភាពនិងតម្រូវការការកសាងសមត្ថភាពទូទៅ<br>• វិធានយេនឌ័រក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ | ជំនាញផ្នែកប្រែប្រួលអាកាសធាតុនិងហេដ្ឋារចនាសម្ព័ន្ធ<br>• កញ្ញា ទូស សោភ័ណ្ឌ ជំនាញយែនឌ័រ | |
| ១៤៖០០-១៤៖២ | • ការពិភាក្សារួម | • ប្រធានសម្របសម្រួល និង<br>• អ្នកចូលរួមទាំងអស់ | |
| ១៤៖០០-១៤៖២០ | **ការងារសម្របសម្រួល SPCR និងការងារគាំទ្របច្ចេកទេសដល់កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងជនបង្គោលប្រែប្រួលអាកាសធាតុពាក់ព័ន្ធតាមស្ថាប័ន៖**<br>• ហេតុផល និងសេចក្តីផ្តើម<br>• ចំណុចរកឃើញនានាជុំវិញការងារសម្របសម្រួលនេះ និងភាពប្រឈម<br>• លើកជាដំណោះស្រាយតាម៖<br>▪ គោលបំណង និងវិធាន<br>▪ វិសាលភាពការងារ និងការអនុវត្ត និង<br>▪ ប្រសិទ្ធភាព និរន្តរភាព និងតម្រូវការកសាងសមត្ថភាព | • លោកបណ្ឌិត ដោក ដូម៉ា អ្នកជំនាញគ្រប់គ្រងកម្មវិធី MCRDP និង<br>• លោក ជ័ម ប៊ូរីន អ្នកជំនាញអន្តរជាតិគ្រប់គ្រងចំណេះដឹងនិងទំនាក់ទំនង | |
| ១៤៖២០-១៥៖០០ | • សំណួរ និងចម្លើយ | • ប្រធានសម្របសម្រួល និង<br>• អ្នកចូលរួមទាំងអស់ | |
| ១៥៖០០-១៥៖៣០ | • សម្រាកពិសារអាហារសម្រន់ | | |
| ១៥៖៣០-១៦៖០០ | **ការពិនិត្យតាមដានស៊ីជម្រៅផ្នែកយេនឌ័រ និងការវាយតម្លៃគម្រោង វិនិយោគ SPCR និងសមត្ថភាពអ្នកសម្រេចផ្នែកគោលនយោបាយ ព្រមទាំងសង្គមស៊ីវិល៖**<br>• ចំណុចរកឃើញសំខាន់ៗ និងភាពប្រឈម<br>• កត្តាសំខាន់ៗសម្រាប់ដំណើរការ និងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដោយនិរន្តរភាពក្រោមកម្មវិធីយុទ្ធសម្រាប់ភាពធន់នឹងអាកាសធាតុ<br>• លើកជាដំណោះស្រាយតាម៖ | • កញ្ញា ទូស សោភ័ណ្ឌ អ្នកជំនាញយែនឌ័រ<br>• លោក សួន សេន និង<br>• កញ្ញា ប៉ូឡា ស៊ីលវ៉ា អ្នកជំនាញត្រួតពិនិត្យ និងវាយតម្លៃ | |

| | | | |
|---|---|---|---|
| | ▪ បញ្ជីត្រួតពិនិត្យផ្នែកយេនឌ័រក្នុងការតាមដានវាយតម្លៃ<br>▪ ទម្រង់របាយការណ៍រួមនានា<br>▪ ទិន្នន័យដើមគ្រា និងតម្រូវការព័ត៌មានសម្រាប់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ និង<br>▪ តម្រូវការកសាងសមត្ថភាពអ្នកពាក់ព័ន្ធនានា | | |
| ១៦៖០០-១៦៖៤៥ | • ការពិភាក្សាតាមក្រុមស្តីពីការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ | • ប្រធានសម្របសម្រួល និង<br>• អ្នកចូលរួមទាំងអស់ | |
| ១៦៖៤៥-១៧៖១៥ | • របាយការណ៍តាមក្រុម | • ក្រុមការងារធ្វើរបាយការណ៍ | |
| ១៧៖១៥-១៧៖២០ | • សង្ខេបលទ្ធផលប្រចាំថ្ងៃទី១ | • លោក អ៊ូ ច័ន្ទជារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី នៃក្រសួងបរិស្ថាន | |
| **ថ្ងៃទី២៖ ថ្ងៃព្រហស្បត៍ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣** | | | |
| **ផ្នែកទី៣៖ លទ្ធផលទី១៖ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍** | | | |
| ៧៖៣០-៨៖៣០ | • ចុះឈ្មោះអ្នកចូលរួម | | |
| ៨៖៣០-៩៖១៥ | • ចំណុចសំខាន់ៗ និងភាពប្រឈមសម្រាប់ស្ថាប័នមួយដែលមានសមត្ថភាពបច្ចេកទេស និងនិរន្តរភាពក្នុងធ្វើសមាហរណកម្មការបន្សាំទៅក្នុងផែនការអភិវឌ្ឍន៍ ដើម្បីលើកស្ទួយនូវភាពធន់នឹងអាកាសធាតុក្នុងកម្មវិធី ផែនការ និងគោលនយោបាយនានាតាមរយៈការកសាងសមត្ថភាពស្ថាប័នក្នុងការធ្វើផែនការសកម្មភាព និងផែនការថវិកា និងការអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុ<br>• លើកដំណោះស្រាយតាមរយៈ៖<br>▪ វិធាន៖ ប្រើប្រាស់វិធានសរុប វិធានរៀនផងធ្វើផងតាមរយៈការប្រើប្រាស់ឧបករណ៍អនុវត្តជាក់ស្តែង ការសិក្សាជាក់លាក់ណាមួយ និងបទដ្ឋានសិក្សា | • លោក បណ្ឌិត ដោក ដូម៉ា អ្នកជំនាញគ្រប់គ្រងកម្មវិធី និង<br>• កញ្ញា ទូស សោភ័ណ្ឌ អ្នកជំនាញយេនឌ័រ | លោក ស៊ុំ ធី ប្រធាននាយកដ្ឋានប្រែប្រួល អាកាសធាតុ នៃក្រសួងបរិស្ថាន<br><br>បណ្ឌិត អានចា ស្រ៊ីនីវ៉ាសាន ប្រធានក្រុមការងារ និងអ្នកបច្ចេកទេសជាន់ខ្ពស់ ផ្នែកប្រែ |

| | | | |
|---|---|---|---|
| | និងគ្រោងប្លង់ ។ល។<br>▪ ការកំណត់អ្នកចូលរួម៖ អ្នកបច្ចេកទេស អ្នកធ្វើការសម្រេចចិត្តជាន់ខ្ពស់ នៅក្នុងជួររដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងវិស័យឯកជន | | ប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ី<br><br>លោកបណ្ឌិត ប៊ុច សុខេម ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| ០៩៖១៥-០៩-៣០ | • សំណួរ និងចម្លើយ | • ប្រធានសម្របសម្រួល និង<br>• អ្នកចូលរួមទាំងអស់ | |
| **ផ្នែកទី៤៖ លទ្ធផលទី២៖ ការសិក្សាលទ្ធភាពគម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ** (National Adaptation Programme of Action to Climate Change: NAPA) | | | |
| ០៩៖៣០-១០៖១៥ | • របកគំហើញសំខាន់ៗ និងភាពប្រឈមពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ<br>• លើកដំណោះស្រាយតាមរយៈ៖<br>  • ផែនការសកម្មភាពលម្អិតរបស់ការសិក្សាលទ្ធភាពគម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (National Adaptation Programme of Action to Climate Change: NAPA)<br>  • ការកសាងសមត្ថភាពក្នុងការចងក្រងសំណើគម្រោងដែលមានគុណភាពខ្ពស់សម្រាប់ស្នើសុំថវិកាអាកាសធាតុនានា | • លោកបណ្ឌិត ឡាយ ចន្ទី<br>• លោកបណ្ឌិត ចែម ផល្លា និង<br>• លោកបណ្ឌិត ភិត ជ័រ ម៉ាណាមី | |
| ១០៖១៥-១០៖៤៥ | • សម្រាកពិសារអាហារសម្រន់ | | |
| ១០៖៤៥-១១៖៤៥ | **ការពិភាក្សាជាក្រុម បែងចែកជា៤ក្រុម៖**<br>• មតិយោបល់ ដែលពាក់ព័ន្ធគម្រោងNAPA និងកម្មវិធីនានា ដូចជាNAP និង<br>• មតិយោបល់ ដែលពាក់ព័ន្ធទៅនឹងវិធាន និងផែនការការងារ | • ប្រធានសម្របសម្រួល<br>• ប្រធានក្រុមនិមួយៗ និង<br>• អ្នកចូលរួមទាំងអស់ | |
| ១១៖៤៥-១២៖៣០ | • លទ្ធផលបង្ហាញរបស់ក្រុមនីមួយៗ និងការពិភាក្សាទូទៅ | • ក្រុមអ្នកធ្វើរបាយការណ៍ | |
| ១២៖៣០-១៣៖៣០ | សម្រាកពិសារអាហារថ្ងៃត្រង់ | | |
| **ផ្នែកទី៥៖ លទ្ធផលទី៣៖ ពង្រឹងការចូលរួមរបស់សង្គមស៊ីវិលដែលពាក់ព័ន្ធនឹងភាពធន់នឹងអាកាសធាតុ** | | | |
| ១៣៖៣០-១៤៖៤៥ | • លទ្ធផលទី៣៖ យន្តការចូលរួមរបស់សង្គមស៊ីវិល | • លោក ហែម ចាន់ធូ មន្ត្រីជាន់ខ្ពស់ធនាគារអភិវឌ្ឍន៍អាស៊ី | |
| | | | |

| | | |
|---|---|---|
| **ផ្នែកទី៦៖ លទ្ធផលទី៤៖ អំពីឯកសារចំណេះដឹង និងការផ្សព្វផ្សាយ** | | |
| ១៤៖៤៥-១៥៖១៥ | **ផែនការការចូលរួមពីអ្នកពាក់ព័ន្ធ និងទំនាក់ទំនង៖**<br>• របកគំហើញសំខាន់ៗ និងភាពប្រឈម<br>• លើកផែនការសកម្មភាពទំនាក់ទំនង និងការចូលរួមពីអ្នកពាក់ព័ន្ធ | • លោកស្រី យូ ប៉ោនី និង<br>• លោក ជ័ម ប៊ូរីន អ្នកជំនាញផ្នែកគ្រប់គ្រងចំណេះដឹង និងទំនាក់ទំនង |
| ១៥៖១៥-១៥៖៣០ | • សម្រាកពិសាអាហារសម្រន់ | |
| ១៥៖៣០-១៦៖០០ | • ពិភាក្សារួម៖<br>• ការចូលរួមពីអ្នកពាក់ព័ន្ធ និងទំនាក់ទំនង<br>• យន្តការ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ | • ប្រធានសម្របសម្រួល និង<br>• អ្នកចូលរួមទាំងអស់ |
| ផ្នែកទី៧៖ សរុបលទ្ធផល និងបិទអង្គសិក្ខាសាលា | | |
| ១៦៖០០-១៦៖៣០ | **សរុបលទ្ធផល៖**<br>• ចំណុចគន្លឹះៗ និងអនុសាសន៍រួមដែលទាញចេញពីអង្គសិក្ខាសាលា និង<br>• ជំហានបន្ទាប់<br>▪ បញ្ចប់របាយការណ៍ចាប់ផ្តើម និងលទ្ធផលផែនការសកម្មភាព នានាៗ<br>▪ ដំណើរការអនុវត្ត និងការធ្វើរបាយការណ៍ និងដំណើរការទំនាក់ទំនង និង<br>▪ ការត្រៀមអនុវត្តជាក់ស្តែងនានា | • លោកបណ្ឌិត ប៉ិច សុខេម ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ |
| ១៦៖៣០-១៧៖០០ | • កំណត់សម្គាល់បញ្ចប់-មតិយោបល់ និងអនុសាសន៍នានាសន្ទរកថាបិទអង្គសិក្ខាសាលា | • ឯកឧត្តម ស៊ិន ខ័ណ្ឌី អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន<br>• បណ្ឌិត អានចា ស្រីនីវ៉ាសាន់ ប្រធានក្រុមការងារ និងជាអ្នកជំនាញការប្រែប្រួលអាកាសធាតុជាន់ខ្ពស់ ធនាគារអភិវឌ្ឍន៍អាស៊ី<br>• លោកបណ្ឌិត ប៉ិច សុខេម ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ |

**កំណត់សម្គាល់៖ សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់៕**

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

## Ministry of Environment
### Climate Change Department
**Mainstreaming Climate Resilience into Development Planning (MCRDP)**

# សិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅក្នុង ការរៀបចំផែនការអភិវឌ្ឍន៍ ថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ

# Inception Workshop on Mainstreaming Climate Resilience into Development Planning on 4-5 December 2013, Phnom Penh Hotel, Phnom Penh, Cambodia

| ល.រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | ភេទ | តួនាទី | ក្រសួង ស្ថាប័ន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| 1 | | A. Sano | M | Consultant | | 012 599817 |
| 2 | អំ ភិរម្យ | Am PhiRum | M | អនុប្រធាន នាយកដ្ឋាន | GDA/MAFF | 011 927862 |
| 3 | | Archana datta | F | Consultant | Hatfiled | |
| 4 | ប៊ិន ជីវ័ន្តមុនីរះ | Bin Chivonmoniras | M | យុវជន | ក.ស.ឃ.ក ខ័ណ្ឌទួលគោក | 017 557965 |
| 5 | ចា ស៊ុលលី | Cha Sully | M | Vice Officer | MOE | 012 553969 |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ចម និម្មល | Cham Nimul | F | USS | MOC | 017 333888 |
| 7 | ច័ន្ទ ខែមនាថ | Chan KhemNeat | F | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន | 011 861007 |
| 8 | ច័ន្ទ មិថុនា | Chan Mithouna | M | យុវជន | ស.ស.យ.ក | 012 568955<br>093 212828 |
| 9 | ជា ចន្ទន៍ធូ | Chea ChanThou | M | អនុប្រធាន<br>នាយកដ្ឋាន | ក្រសួងបរិស្ថាន | 011 750758 |
| 10 | ជា សន្តាន | Chea Sandan | F | មន្ត្រីយេនឌ័រ | DPA | 012 948775 |
| 11 | ជា សុខុន | Chea Sokhon | M | មន្ត្រី | FA/MAFF | 011 956 577 |
| 12 | ចែម ផល្លា | Chem Phalla | M | NAPA Consultants | Hatfiled | 012 966850 |
| 13 | ឆេន វិទូ | Chhen Vitou | M | យុវជន | ស.ស.យ.ក<br>ខណ្ឌទួលគោក | 085 441111 |
| 14 | ឈឹម សុគន្ធ | Chhim Sokun | M | អគ្គនាយករង | ក្រសួងរៀបចំដែនដី<br>នគរូបនីយកម្ម និង<br>សំណង់ | 012 936916 |
| 15 | ឈាន់ ឡុងឌី | Chhorn Lundi | M | ប្រធានការិយាល័យ | ក្រសួងពាណិជ្ជកម្ម | 088 8686333 |
| 16 | ឈួន ភ័ក្ត | Chhoun Pheak | M | Manager | GADC | 012 995866 |
| 17 | ឈុន សីហា | Chhun Seiha | M | Vice Office | ក្រសួងបរិស្ថាន | 011 337787 |
| 18 | | Chin Phirundeth | F | Receiptionist | ADB | |
| 19 | ជូ ហ៊ុនហៀន | Chou Bunheang | M | ប្រធាននាយកដ្ឋាន | ក.ក.ជ | 011 898038 |
| 20 | ជួន ប៊ុនរឿន | Choun Bunroeun | M | យុវជន | ស.ស.យ.ក<br>ខណ្ឌ ឫស្សីកែវ | 092 378837 |
| 21 | ជួន លក្ខិណា | Chuon Leakhena | F | យុវជន | UYFC | 067 532222 |
| 22 | បណ្ឌិត កែវ សុជីវី | Dr. Kao Sochivi | F | DDG | រដ្ឋបាលព្រៃឈើ | 012 202805 |

| | | | | | | |
|---|---|---|---|---|---|---|
| 23 | អ៊ូ ស៊ីវីតា | Dr. Ou Sivita | F | DDG | រដ្ឋបាលព្រៃឈើ | 012 914764 |
| 24 | បណ្ឌិត សេង លីម៉េង | Dr. Seng Lymeng | M | ទីប្រឹក្សា | ក្រសួងអភិវឌ្ឍន៍ជនបទ | 012 926333 |
| 25 | ឌី ច័ន្ទតារា | Dy Chandara | F | មន្ត្រីរដ្ឋបាល | | 097 966886 |
| 26 | | Emanvele Wccucato | M | M&E Advicsor | CCCA | |
| 27 | អេង គឹមសាន | Eng Kimsan | M | អគ្គាធិការរង | ក្រសួងបរិស្ថាន | 017 277717 |
| 28 | ហាក់ យូ | Hak You | M | Infra Specialist | MoE | 012 290690 |
| 29 | | Hartmut Krugmann | M | Consultant | Hatfiled | |
| 30 | ហាយ នារីរ័ត្ន | Hay NearyRath | F | លេខាធិការ | ក្រសួងបរិស្ថាន | 098 837387 |
| 31 | ហែម ច័ន្ទរិទ្ធី | Hem Chanrithy | M | មន្ត្រី | FA/MAFF | 077977608 |
| 32 | ហែម ចាន់ធូ | Hem Chanthou | M | Senior Prog. Officer | ADB | |
| 33 | ហែម រិទ្ធី | Hem Rithy | M | អនុប្រធាន | ខណ្ឌដូនពេញ | 012 629943 |
| 34 | ហេង បូណេ | Heng Baurna | M | GBS Specialist | Hatfiled | 017 990957 |
| 35 | ហេង បូរាណ | Heng Buran | M | GIS Specialist | Hatfiled | 017 220 957 |
| 36 | ហេង សុភាព | Heng Sopheap | M | សាស្ត្រាចារ្យ | សកលវិទ្យាល័យជាតិគ្រប់គ្រង | 012 848900 |
| 37 | | Hou Kalyan | F | | ក្រសួងបរិស្ថាន | |
| 38 | ហ៊្វត ហ៊ុយ | Huot Huy | M | អនុប្រធាន ស.ស.យ.ក មានជ័យ | UYFC | 012 325 333 |
| 39 | អ៊ឹម ផលឡៃ | Im Phallay | F | Environment Program Manager | NGO Forum | |
| 40 | អ៊ឹម សុផាណ្ណា | Im Sophanna | M | Chief Office | MoWRAM | |
| 41 | | In Sothea | | Director | ADB | 011 246966 |

| | | | | | | |
|---|---|---|---|---|---|---|
| 42 | អ៊ិត កេសនា | Ith Kessna | M | V.Chief | MOE | 070 888866 |
| 43 | | Jim Webb | M | Consutltant | Hatfiled | |
| 44 | | JulienBrewster | M | REAA & M&E Advisor | PACT | |
| 45 | | Kang Boran | M | | MFE | 012 583811 |
| 46 | កែ វង្សវឌ្ឍនា | Ke Vongwathana | M | អគ្គនាយករង | ក្រសួងបរិស្ថាន | 017 448366 |
| 47 | គេន សារ៉ន | Ken Sarorn | M | យុវជន | ខណ្ឌសែនសុខ | 089 673524 |
| 48 | កែវ ណារ៉េន | Keo Naren | M | យុវជន | ស.ស.យ.ក រាជធានីភ្នំពេញ | 012 225 322 |
| 49 | ខាំ ចាន់សុភ័ក្រ | Kham Chansopheak | M | យុវជន | ស.ស.យ.ក ខណ្ឌចំការមន | 088 8999984 |
| 50 | ឃឹម សណ្ដាប់ | Khim Sandab | M | មន្ត្រី | GSGG | 012 360 907 |
| 51 | ឃឿន សុខុម | Khoeun Sokhom | M | Assitant to Under Secreatary of State | MOWRAM | 016856677 |
| 52 | ឃុន កក្កដា | Khun Kakada | M | Deputy Director | MAFF/GDR | 016 331638 |
| 53 | | Kim Menglim | M | Specialist | USAID | |
| 54 | កុប ម៉ាត់ | Kob Math | M | Specialist | ADB | 077 414477 |
| 55 | គល់ សម្បត្តិ | Kol Sambat | M | មន្ត្រី | ក្រសួងបរិស្ថាន | |
| 56 | គង់ ចាន់ថន | Kong Chanthan | M | ទីប្រឹក្សា | NCDDS | 012 898557 |
| 57 | គង់ ចែមសុផា | Kong Chemsopha | M | យុវជន | ស.ស.យ.ក ខណ្ឌ ឬស្សីកែវ | 012 628 326 |
| 58 | គង់ មុនីពិសិដ្ឋ | Kong Monypiseth | M | អនុប្រធាននាយកដ្ឋាន | ក្រសួងផែនការ | 011 232333 |

| | | | | | | |
|---|---|---|---|---|---|---|
| 59 | គុយ ភឿន | Kuy Phoeurn | M | Official | ក្រសួងបរិស្ថាន | 092 234944 |
| 60 | ឡាយ ចន្ធី | Lay Chanthy | M | ទីប្រឹក្សា | ក្រសួងបរិស្ថាន | 089 793307 |
| 61 | ឡេង ហ៊ុយសៀង | Leng HuySeang | M | | | 093 683398 |
| 62 | ឡេង គឹមស្រេង | Leng Kimsreng | M | គណៈកម្មការផ្សារអូឫស្សី | ៧ មករា | 012 757593 |
| 63 | ឡេង វី | Leng Vy | M | អនុរដ្ឋលេខាធិការ | MOI | 012 353544 |
| 64 | លឹម គឹមលាប | Lim Kimleap | F | យុវជន | ស.ស.យ.ក រាជធានីភ្នំពេញ | 012 555847 |
| 65 | ឡុង ចិន | Long Chen | M | មន្ត្រី | ក្រសួងបរិស្ថាន | 077 907788 |
| 66 | ឡុង សុខា | Long Sokha | M | ប្រធាននាយកដ្ឋាន | គ.វ.ម | 012 936325 |
| 67 | លឺ ស៊ីមអ៊ាម | Lu SimEam | M | អនុរដ្ឋលេខាធិការ | MRD | 012 936636 |
| 68 | | Lun Bona | M | IEC Officer | SCW | 070 907 181 |
| 69 | លី ណូរ៉ាត់ | Ly Norath | M | រដ្ឋបាល | ស.ស.យ.ក | 015 202015 |
| 70 | លី សាវុន | Ly Savun | F | មន្ត្រី | ក្រសួងបរិស្ថាន | 010 929169 |
| 71 | លី សុផាន់ណា | Ly Sophana | M | គ្រូបង្រៀន | សកលវិទ្យាល័យបញ្ញាសាស្ត្រ | 012 786531 |
| 72 | លី សុភ័ណ្ឌ | Ly Sophorn | F | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន | 016 863455 |
| 73 | ម៉ាក់ សុផល | Mak Sophal | F | យុវជន | ស.ស.យ.ក ខណ្ឌ ដង្កោ | 089 345945 |
| 74 | | Marko Kesuinen | M | Researcher | | |
| 75 | មាន ពន្លឺ | Mean Ponle | M | | | 093 937298 |
| 76 | មាស ចាន់ទី | Meas Chanty | M | Senior GRET | GRET | 012 586862 |

| | | | | | | |
|---|---|---|---|---|---|---|
| 77 | មាស សុផល | Meas Sophal | M | Program Director | MOE | 017 926937 |
| 78 | ម៉ែន ចាន់បូណា | Men Chanbona | M | M&E Officer | Live & Learn Cambodia | 017 330 740 |
| 79 | ម៉ឺន ម៉ាឡែន | Meun Malen | F | យុវជន | UYFC | 017 488553 |
| 80 | មិន ប៊ុណ្ណារ៉ា | Min Bunnara | M | WSM Specialist | FFI | 012 839 960 |
| 81 | ម៉ប់ សារ៉េត | Mob Sareth | M | យុវជន | ស.ស.យ.ក ខណ្ឌ៧ មករា | 012 907926 |
| 82 | ម៉ុង ស៊ាងងឹម | Mong Seangngim | M | អគ្គនាយករង | RAC | 077 981819 |
| 83 | បូល សំនៀង | Moul Samneang | F | Senior Prog. Officer | The Asia Foundation | 012 833316 |
| 84 | មុន ដួងរតនៈ | Mun Duong Ratanak | M | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន | |
| 85 | នៅ ស្រីរ័ត្ន | Neou Sreyroth | F | | ក្រសួងបរិស្ថាន | |
| 86 | ង៉ែត បុល | Nget Bol | M | Vice Chief Officer | ក្រសួងបរិស្ថាន | 012 785553 |
| 87 | ង៉ែត សុវណ្ណ | Ngeth Sovann | M | Deputy Director | MOH | 012 883 161 |
| 88 | ញ៉ែម សុខា | Nhem Sokha | M | Deputy Director | DAENG/GDA | 012 538 595 |
| 89 | ញ៉ែម សុវណ្ណរិទ្ធ | Nhem SovanaRith | M | យុវជន | ស.ស.យ.ក ខណ្ឌដង្កោ | 096 3503153 |
| 90 | ញ៉ែម វណ្ណរិទ្ធ | Nhem Vannarith | M | យុវជន | ស.ស.យ.ក ខណ្ឌដង្កោ | 096 350 3153 |
| 91 | ញ៉ែម វណ្ណយុត្តិ | Nhem Vannayuth | M | Officer | DPA | 016 490800 |
| 92 | | Nob Makara | M | Office Manager | Khmer Solar | 089 676838 |
| 93 | ណុប សុធារិទ្ធ | Nop SotheaRith | M | អនុប្រធាននាយដ្ឋាន | ក្រសួងបរិស្ថាន | 017 672978 |
| 94 | នុត សម្បត្តិ | Nouth Sambath | M | អគ្គនាយករង | RAC | 012 851423 |
| 95 | នូវ ផល្លីន | Nouv Phalin | M | | MOE | 070 733529 |
| 96 | នុត ច័ន្ទសុខា | Nuth ChanSokha | M | អនុរដ្ឋលេខាធិការ | MOP | 012 373838 |

| | | | | | | |
|---|---|---|---|---|---|---|
| 97 | អ៊ូ ច័ន្ទធារិទ្ធ | Ou Chanthearith | M | អនុប្រធាននាយដ្ឋាន | ក្រសួងបរិស្ថាន | 017 978 879 |
| 98 | អ៊ុក ណាវ៉ាន់ | Ouk Navann | M | Deputy Director General | ក្រសួងបរិស្ថាន | 011 845845 |
| 99 | អ៊ុំ ពិសី | Oum Pisey | M | ប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន | 097 6725859 |
| 100 | | Paula Silva | F | M&E Specialist | Hatfiled | |
| 101 | | Peter Brimble | M | Deputy CD | ADB | |
| 102 | | Peter Minamee | M | Consultant | Hatfiled | |
| 103 | ភិន ណារ៉ុង | Phin Narong | M | ប្រធានផ្នែករដ្ឋបាល | UYFC Phnom Penh | 012 225215 |
| 104 | ភូ អ៊ីវ | Phou Iv | M | Senior Officer | Amret | 012 371 274 |
| 105 | ប៉ូច គង់ឆេង | Poch Kongchheng | M | Properity Officer | British Embassy | 017 333650 |
| 106 | ព្រំ ជិន | Prum Chin | M | អនុប្រធាននាយដ្ឋាន | ក្រសួងព័ត៌មាន | 012 590 272 |
| 107 | រស់ សីលវ៉ា | Ros Seilava | M | អនុរដ្ឋលេខាធិការ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| 108 | សរ ច័ន្ទតូរ៉ា | Sar Channtora | M | HRM | MRG | 016 888399 |
| 109 | សាយ៉ា ម៉ារតា | Saya Marta | F | CSA Program Advisor | SNV | 012 238817 |
| 110 | | Scott Cunliffe | M | Consultant | Hatfiled | |
| 111 | សេង លីម៉េង | Seng Lymeng | M | ទីប្រឹក្សា | ក្រសួងអភិវឌ្ឍន៍ជនបទ | 012 962 333 |
| 112 | សេង សុភាព | Seng Sopheap | M | ជំនួយការ | NBP | 015 662 977 |
| 113 | ស៊ីម ទូច | Sim Touch | M | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន | 012 425 346 |

| | | | | | | |
|---|---|---|---|---|---|---|
| 114 | សូ ពុទ្ធា | So Putha | M | Deputy Director of CCD | MOE | |
| 115 | សុខ ហេង | Sok Heng | M | Director | Resarch Institute | 012 639961 |
| 116 | សុខ សិរីបុត្រ | Sok Seryboth | M | យុវជន | ស.ស.យ.ក | 011 226789 |
| 117 | | Sokhem Pech | M | Team Leader | TA, MOE | 012 833533 |
| 118 | សុំ មនោរម្យ | Som  Moonorum | M | អនុប្រធានក្រុម | UYFC | 012 533070 |
| 119 | សុង ទីនណា | Song Tinna | M | យុវជន | ខណ្ឌសែនសុខ | 016 226444 |
| 120 | សរ កុសល | Sor Kosal | M | ប្រធាននាយកដ្ឋាន | CDC | |
| 121 | ស៊ន ស៊ុនសុភក្តី | Sorn Sunsopheak | M | ប្រធានការិយាល័យ | NCDDS | 012 922123 |
| 122 | សួន សំអូន | Soun SamAun | M | ប្រធានការិយាល័យ | ក្រសួងធនធានទឹក និង ឧតុនិយម | 012 877924 |
| 123 | | Srey Channann | M | Office Manager | Mekong Carbon Co.,Ltd | 088 8383329 |
| 124 | ស្រុន វិសាល | Srun Visal | F | អនុប្រធាន អចិន្ត្រៃយ៍ សសយក | DP | 016 800353 |
| 125 | ស៊ុំ ធី | Sum Thy | M | ប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន | |
| 126 | ស៊ុន ប៊ុនណា | Sun Bunna | M | Deputy Director | MOWYS | 012 868656 |
| 127 | ស៊ុន គង់ | Sun Kong | M | អ្នកសម្របសម្រួល | IUCN | 012 755501 |
| 128 | ស៊ុន វុទ្ធី | Sun Vuthy | M | មន្ត្រី | MOE | 012 784 715 |
| 129 | ស៊ឹង សុផល | Sung Sophal | M | Director | BBU | 098 626626 |
| 130 | សួស សេង | Suon Seng | M | TA M&E | MOE | 097 8364545 |
| 131 | សួស ប៊ុនថន | Suos Bunthan | M | Deputy Director | CNMC | 089 903030 |

| | | | | | | |
|---|---|---|---|---|---|---|
| 132 | សួស ប្រាថ្នា | Suos Prathna | M | អគ្គនាយករង | ក្រសួងមហាផ្ទៃ | 012 991088 |
| 133 | តន់ វ៉ាន់ថារ៉ា | Tan Vanthara | M | Secreatary of State | MOWRAM | 017 353558 |
| 134 | តាយ សុទ្ធី | Tay Sothy | M | អនុប្រធាន | ស.ស.យ.ក<br>ខណ្ឌ ពោធិសែនជ័យ | 077 833 779 |
| 135 | | Teng Sovanny | F | Fin&Admin Assistant | ADB | |
| 136 | ថាច់ សុបិន | Thach Sobeon | M | មន្ត្រី | ក្រសួងបរិស្ថាន | 097 9269267209 |
| 137 | | Than Rithy | M | PC | SCO | 012 919333 |
| 138 | ធឿន ចាន់ផល្លិកា | Thoeun ChanPhallika | F | មន្ត្រី | CDC | 012 247532 |
| 139 | ថុល ឌីណា | Thol Dina | M | PhD | University | |
| 140 | | Thomas Bovin | M | Knowledge Management and Communication Specialist | Hatfiled | |
| 141 | ទឹម ម៉ានី | Tim Many | M | អគ្គាធិការរង | ក្រសួងបរិស្ថាន | 012 590 272 |
| 142 | ទិន ពន្លក | Tin Ponlok | M | អគ្គនាយករង | ក្រសួងបរិស្ថាន | |
| 143 | ទូច រ៉េណា | Touch Rena | M | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន | 017 890 287 |
| 144 | ទូស សោភ័ណ្ឌ | Tous Sophorn | F | Gender Specialist | Hatfiled | 012 843041 |
| 145 | ទួន រតនា | Tuon Rathana | M | Officer | ស.ស.យ.ក<br>រាជធានី | 012 558883 |
| 146 | ទុយ ភាពរៈ | Tuy Pheaprak | M | Deputy Director | M.F.A | 012 225592 |

| | | | | | | |
|---|---|---|---|---|---|---|
| 147 | អ៊ូ ស៊ីរីតា | U Sirita | F | DDG | FA/MAFF | 012 914 764 |
| 148 | វ៉ាន សុខជា | Van Sokchea | M | MIS | Hatfiled | 012 863183 |
| 149 | | Vann monyneath | M | DDG | ក្រសួងបរិស្ថាន | 012 203456 |
| 150 | វណ្ណា សុវិទូ | Vanna Souvitou | M | យុវជន | ស.ស.យ.ក | 089 215 171 |
| 151 | វង់ ចែមសុផា | Vong ChemSopha | M | យុវជន | ស.ស.យ.ក ខណ្ឌឫស្សីកែវ | 012 628326 |
| 152 | វង្ស ពិសិដ្ឋ | Vong Pisith | M | អគ្គនាយករង | MPWT | 012 833611 |
| 153 | យូ ប៉ោនី | You Porny | F | KM &Commnication Specialist | ក្រសួងបរិស្ថាន | 012 617092 |
| 154 | ហោ សោភា | | M | ប្រធានរដ្ឋបាល | ក្រសួងបរិស្ថាន | 012 736789 |
| 155 | ហោ សុភាព | | M | រដ្ឋលេខាធិការ | ក្រសួងព័ត៌មាន | |

ឧបសម្ព័ន្ធទី៣៖

**សុន្ទរកថា**
**ឯកឧត្តម ស៊ិន ច័ណ្ឌី អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន**
**ក្នុងពិធីបើកសិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោងការបញ្ជ្រាប**
**ភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍**
**សណ្ឋាគារភ្នំពេញ ថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៣**

- *សូមគោរពឯកឧត្តម លោកជំទាវ សមាជិកសមាជិកា នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ*
- *ឯកឧត្តម រស់ សីលវ៉ា អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *លោក ភីធើ ប្រ៊ីមប៉ល នាយករងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានសិក្សា និងក្មួយៗយុវជន យុវនារី និងនិស្សិតទាំងអស់ជាទីមេត្រី!*

តាងនាមឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយសសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងមោទនភាពបំផុតដែលបានចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (Strategic Program for Climate Resilience: SPCR) នៅកម្ពុជានាពេលនេះ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណជាអនេកកប្បការចំពោះវត្តមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិក សមាជិកានៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ សមាជិកក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានសិក្សានានា និងវិស័យឯកជន ក៏ដូចជាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងញ៉ាំងឱ្យអង្គសិក្ខាសាលានេះប្រព្រឹត្តទៅក្នុងស្មារតីសហប្រតិបត្តិការខ្ពស់ ជាពិសេសការផ្សាភ្ជាប់នូវទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធ និងរឹងមាំថែមទៀតក្នុងការចូលរួមអនុវត្តគម្រោងវិនិយោគនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុដំណាក់កាលទី២។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់មូលនិធិវិនិយោគអាកាសធាតុ ដែលបានបន្តផ្តល់ជំនួយហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទាន តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលបានសហការ និងគាំទ្រយ៉ាងពេញទំហឹងលើការអនុវត្តកម្មវិធីនេះ ជាពិសេស

គម្រោងការបញ្រ្ជាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នៃកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗយុវជន យុវនារីទាំងអស់ជាទីមេត្រី!***

ដូចដែលយើងទាំងគ្នាបានជ្រាបស្រាប់ហើយថា ការប្រែប្រួលអាកាសធាតុត្រូវបានពិភពលោកទទួលស្គាល់

ជាបញ្ហាសកល។ កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស បានធ្វើឱ្យមានកំណើនកំដៅលើភពផែនដី ដែលជាមូលហេតុដ៏ចម្បងនៃការប្រែប្រួលអាកាសធាតុ ជារួមរបស់ផែនដី។ តាមការព្យាករណ៍បានឱ្យដឹងថា កំដៅភពផែនដីនឹងកើនឡើងពី១.៥°C ដល់២°C នៅចុងសតវត្សរ៍ទី២១ បើធៀបទៅនឹងសីតុណ្ហភាពនៅចុងសតវត្សរ៍ទី១៩។ ជាការពិតណាស់ ការប្រែប្រួលអាកាសធាតុនេះអាចនឹងជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច សង្គម បរិស្ថាន និងជីវៈចម្រុះ ទាំងនៅក្នុងប្រទេសអភិវឌ្ឍ ប្រទេសកំពុងអភិវឌ្ឍ ក៏ដូចជាប្រទេសអភិវឌ្ឍតិចតួច។

ថ្មីៗនេះក្នុងឱកាសវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានមានប្រសាសន៍ប្រកបដោយអត្ថន័យថា ការប្រែប្រួលអាកាសធាតុលែងជារឿងអ្វីដែលនៅឆ្ងាយពីយើងទៀតហើយ និងកំពុងបង្កឥទ្ធិពលមកលើយើងទាំងអស់គ្នាក្នុងពេលបច្ចុប្បន្ន និងជាបញ្ហាប្រឈមនៅក្នុងសតវត្សរ៍ទី២១នេះ ដោយសារផលប៉ះពាល់របស់វាកាន់តែធ្ងន់ធ្ងរឡើងៗ ហើយមានវិសាលភាពធ្ងន់ជាងមុន។ កម្ពុជាជាប្រទេស ងាយទទួលរងនូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដោយសារសមត្ថភាពបន្សាំនៅមានកម្រិត និងដោយសារតែមូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសយើងមានភាពអាស្រ័យដោយផ្ទាល់ទៅលើវិស័យកសិកម្ម និងធនធានទឹក ហើយហេដ្ឋារចនាសម្ព័ន្ធរូបវន្តក៏នៅមិនទាន់បានបញ្ចូលការគិតគូរពីភាពធន់នឹងការប្រែប្រួលអាកាសធាតុ ជាពិសេសយើងក៏នៅខ្វះខាតបច្ចេកវិទ្យាសមស្រប និងធនធានហិរញ្ញវត្ថុសម្រាប់ដោះស្រាយបញ្ហាប្រឈមនឹងការប្រែប្រួលអាកាសធាតុនេះនៅឡើយ។

***អង្គពិធីទាំងមូលជាទីមេត្រី***

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការងារប្រែប្រួលអាកាសធាតុជាបញ្ហាអាទិភាពមួយ ដូចមានកំណត់នៅក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យយើងទាំងអស់គ្នា រួមគ្នាដោះស្រាយបញ្ហានេះ តាមរយៈការពង្រឹងសមត្ថភាពបន្សាំ ដើម្បីធានាបាននូវភាពធន់ទៅនឹងហានិភ័យនានា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។ ជាមួយនេះផងដែរ យើងក៏ត្រូវផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើការពង្រឹងសមត្ថភាពស្ថាប័ន ក៏ដូចជាធនធានមនុស្សទាំងក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា។

ការអនុវត្តសកម្មភាពកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា បាននិងកំពុងអនុវត្តលើគម្រោងវិនិយោគចំនួន៧ ក្នុងវិស័យធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ដែលអនុវត្តដោយក្រសួង ស្ថាប័នសំខាន់ៗ និងគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស១ ដែលអនុវត្តដោយក្រសួង

បរិស្ថាន សហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអនុវត្តនៃគម្រោងទាំងនេះ។

ខ្ញុំយល់ថា ផ្តើមចេញពីការអនុវត្តកម្មវិធីវិនិយោគនៃកម្មវិធីយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុ និងគម្រោងប្រតិបត្តិការនេះ ក្នុងវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធ ប្រជាជនកម្ពុជាយើងនឹងទទួលបាននូវការរក្សាសន្តិសុខស្បៀង ធានាបាននូវផលិតផលស្រូវខ្ពស់ និងដំណាំដែលធន់នឹងការប្រែប្រួលអាកាសធាតុ។

ខ្ញុំសង្ឃឹមថា ការអនុវត្តគម្រោងខាងលើនេះ នឹងអាចឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នៃរាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) និងរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដែលបញ្ចេញកាបូនតិច សំដៅបង្កើនជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ដើម្បីសម្រេចបានចក្ខុវិស័យខាងលើនេះ ទាមទារឱ្យយើងយកចិត្តទុកដាក់ខ្ពស់ចំពោះការពង្រឹងសមត្ថភាពស្ថាប័ន ក៏ដូចជា ធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងនៅក្នុងការគ្រប់គ្រងធនធានមនុស្ស ការផ្ទេរចំណេះដឹង និងការទទួលយកចំណេះដឹង។ កត្តាទាំងបីនេះមិនអាចខ្វះមួយណាបានឡើយ ហើយមានភាពអាស្រ័យលើគ្នាយ៉ាងជិតស្និទ្ធ ដែលជាកត្តាកំណត់ធានាដល់ការកសាងសមត្ថភាពប្រកបដោយប្រសិទ្ធិភាពខ្ពស់ស្របតាមបច្ចេកវិទ្យាទំនើបថ្មីៗ។ ក្នុងន័យនេះ ខ្ញុំយល់ឃើញថា អង្គសិក្ខាសាលារយៈពេល២ថ្ងៃនេះ នឹងបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងសមត្ថភាពយល់ដឹងរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញបច្ចេកទេសនៅក្នុង គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។

ការស្វះស្វែងរកហិរញ្ញប្បទានបន្ថែមទៀត ពីគ្រប់ភាគីទាំងអស់ ទាំងអង្គការសង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ក៏នៅជាអទិភាពសម្រាប់ប្រទេសកម្ពុជា។ ការសិក្សាលទ្ធភាពកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលនឹងជ្រើសរើសគម្រោងអទិភាពសម្រាប់ដាក់ស្នើសុំថវិកាបន្ថែមនាពេលខាងមុខ តាមរយៈគម្រោង គឺមានសារៈសំខាន់បំផុត ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមនឹងការប្រែប្រួលអាកាសធាតុ ។

ជាមួយគ្នានេះដែរ ការចែករំលែកព័ត៌មាន និងព័ត៌មានក្នុងការបង្កើនសមត្ថភាព ការផ្តល់ព័ត៌មានជូនដំណឹងទុកជាមុន ទាន់ពេលវេលា និងមានប្រសិទ្ធិភាព អំពីភាពរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ ដល់អ្នកពាក់ព័ន្ធទាំងអស់ ជាបញ្ហាសំខាន់បំផុតក្នុងការចូលរួមកាត់បន្ថយបាត់បង់នូវសេដ្ឋកិច្ចជាតិ គ្រួសារ និងអាយុជីវិតមនុស្ស សត្វ សម្រាប់ជាតិ តំបន់ និងសកលលោក។

ខ្ញុំសូមផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ ត្រូវខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ទាំងកម្លាំងកាយ ចិត្ត និងប្រាជ្ញា ដើម្បីស្តាប់ និងផ្តល់អនុសាសន៍សម្រាប់ធាតុចូលក្នុងការកែលម្អរ និងបំពេញបន្ថែមលើឯកសារការចាប់ផ្តើមគម្រោងនៃការអនុវត្តជំនួយសហប្រតិបត្តិការបច្ចេកទេស ឱ្យកាន់តែបានគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានទាំងអស់គ្នា។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានដល់កិច្ចដំណើរការនៃការអនុវត្តគម្រោងវិនិយោគទាំង៧ និងជំនួយសហប្រតិបត្តិការបច្ចេកទេស១នៅកម្ពុជា។ យើងរំពឹងទុកពីមូលនិធិវិនិយោគអាកាសធាតុ និងធនាគារអភិវឌ្ឍន៏អាស៊ី នឹងខិតខំជួយស្វះស្វែងរកហិរញ្ញប្បទានបែមទៀតពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ប្រទេសកម្ពុជា ក្រោយពីបានសិក្សាលទ្ធភាពកម្មវិធីសកម្មភាពបន្សាំជាតិនឹងការប្រែប្រួលអាកាសធាតុ ដែលអង្គសិក្ខាសាលានឹងត្រូវជ្រើសរើសជាគម្រោងអាទិភាព សម្រាប់ដាក់ស្នើសុំថវិកាបន្ថែមទៀតនាពេលខាងមុខ។

ខ្ញុំសូមឱ្យសិក្ខាសាលានេះ នឹងទទួលបានផ្លែផ្កា និងជោគជ័យតាមគោលបំណង និងលទ្ធផលរំពឹងទុក។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ និងក្មួយៗយុវជន យុវនារីទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃចូលរួមក្នុងអង្គសិក្ខាសាលារយៈពេល២ថ្ងៃនេះ ជួបនូវពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកអង្គសិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោងបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ នៅកម្ពុជាចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

## សុន្ទរកថា
## ឯកឧត្តម ស៊ិន ច័ណ្ឌី អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន
## ក្នុងពិធីបិទសិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោងការបញ្ជ្រាប
## ភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

សណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ថ្ងៃទី៤ដល់ទី៥ ខែធ្នូ ឆ្នាំ ២០១៣

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាទីគោរព*
- *ឯកឧត្តមលោកជំទាវតំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន គ្រឹះស្ថានសិក្សា និងប្អូនៗ យុវជន យុវនារី និស្សិតទាំងអស់ជាទីមេត្រី*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូលជាទីមេត្រី*

តាងនាមឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះអស់ពីដួងចិត្តដល់សមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូល ដែលបានចូលរួមសិក្ខាសាលាយ៉ាងសកម្មរយៈពេលពីរថ្ងៃកន្លងមកនេះ ញ៉ាំងអោយសម្រេចបាននូវលទ្ធផល ជាផ្លែផ្កាគួរជាទីមោទនៈ ។ រាល់អនុសាសន៍ប្រកបដោយខ្លឹមសារសំខាន់ៗ ដែលយើងបានទទួលពីសិក្ខាសាលានេះ គឺជាត្រីវិស័យតម្រង់ទិស និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការអនុវត្តកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នាពេលខាងមុខ។ ខ្ញុំសូមថ្លែងការកោតសសើរចំពោះការខិតខំប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រុមការងារគម្រោង ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំសិក្ខាសាលាស្តីពីការបញ្ជ្រាបភាពធន់អាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នេះប្រកបដោយជោគជ័យ។

យើងទាំងអស់គ្នាបានយល់យ៉ាងច្បាស់ថា ការប្រែប្រួលអាកាសធាតុគឺជាភាពប្រឈមរបស់យើងទាំងអស់គ្នាដែលទាមទារឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងកម្រិតជាតិ ក្រោមជាតិ និងអន្តរជាតិ។ ការចូលរួមនេះត្រូវតែធ្វើឡើងតាមរយៈការបង្កើនសមត្ថភាពស្ថាប័ន និងបច្ចេកទេសដើម្បីធ្វើការបញ្ជ្រាបភាពធន់អាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍។ ក្រោមជំនួយហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសពេលនេះបានផ្តល់ឱកាសឱ្យយើងបានពង្រឹងការយល់ដឹង និងចំណេះដឹង និងសមត្ថភាពសម្របសម្រួលសហការគ្នាដើម្បីសម្រេចនូវទិសដៅអាទិភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ កម្មវិធីយុទ្ធសាស្ត្រ

ជាតិឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា និងតាមវិស័យសំខាន់ៗទាំង៩ និងគោលនយោបាយពាក់ព័ន្ធឯទៀត។

*ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ប្អូនៗយុវជន យុវនារី ជាទីរាប់អាន!*

ដូចខ្ញុំបានលើកឡើងនៅក្នុងពិធីបើកសិក្ខាសាលា ការប្រែប្រួលអាកាសធាតុនាសម័យអង្គរ គឺភាគច្រើនបណ្តាលមកពីការប្រែប្រួលពីធម្មជាតិ។ ប៉ុន្តែការប្រែប្រួលអាកាសធាតុនាសម័យបច្ចុប្បន្ននេះ គឺខុសពីសម័យមុនបដិវត្តឧស្សាហកម្មនៅសតវត្សរ៍ទី១៨នៅអឺរ៉ុប។ ការប្រែប្រួលអាកាសធាតុរយៈពេលវែង និងការផ្លាស់ប្តូរធាតុអាកាសរយៈពេលខ្លីបច្ចុប្បន្ននេះ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ទន្លេ និងទឹកជំនន់ភ្នំ និងខ្យល់ព្យុះ បណ្តាលមកពីសកម្មភាពមនុស្សទាក់ទងទៅនឹងការដុតប្រេង និងគ្រឿងចំហេះ និងការផ្លាស់ប្តូររបៀបប្រើប្រាស់ដីនិងតំបន់ព្រៃ។ ប្រទេសកម្ពុជា ចូលរួមចំណែកតិចតួច ដល់ការបង្កឲ្យមានការប្រែប្រួលអាកាសធាតុ ក៏ប៉ុន្តែជាប្រទេសងាយរងគ្រោះដោយសារសេដ្ឋកិច្ច និងប្រជាពលរដ្ឋយើងជាង៨០% ពឹងពាក់យ៉ាងខ្លាំងលើកសិកម្មនិងធនធានទឹក។ ដូចនេះ ការសហការគ្នា និងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ពីបណ្តាប្រទេសអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុនានា គឺជាការចាំបាច់បំផុត។

ការកសាងភាពធន់លើវិស័យទាំង៣ជាអាទិភាព ដូចជាធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធក្រុង និងជនបទ អាចរួមចំណែកយ៉ាងសកម្មក្នុងការកាត់បន្ថយការខូចខាតផ្នែកសេដ្ឋកិច្ច និងការខូចខាងផ្នែកសង្គម បរិស្ថាន និងវប្បធម៌របស់ជាតិ និងប្រជាជនយើង។ ការគ្រប់គ្រងធនធានទឹក កសិកម្ម និងសំណង់ហេដ្ឋារចនាសម្ព័ន្ធត្រឹមត្រូវ និងយូរអង្វែង និងជួយដល់ការអភិវឌ្ឍជាតិ ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ យើងទាំងអស់គ្នា នៅចាំថាក្រោយពីទឹកជំនន់ធំនៅឆ្នាំ២០០០ ស្ពានមួយចំនួននៅតាមដងផ្លូវជាតិលេខ៦A បានត្រូវកាត់ផ្តាច់ដោយសារទឹកជំនន់។ ដោយមានជំនួយពីប្រទេសជប៉ុន ស្ពានទាំងអស់នោះ បានកសាងឡើងវិញ ដោយបានគិតគូរពីភាពធន់នឹងទឹកជំនន់ ដែលនៅគង់វង្សរហូតដល់សព្វថ្ងៃ ថ្វីបើមានទឹកជំនន់ធំនៅឆ្នាំ២០១១ និង២០១៣ នេះ។

ការប្រែប្រួលអាកាសធាតុ នាំមកនូវហានិភ័យ និងកាលានុវត្តភាព សម្រាប់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ។ កត្តានេះ ញាំងអោយឃើញអំពីតួនាទីដ៏សំខាន់របស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធអោយបានយូរអង្វែង។ ប្រសិនបើវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ជោគជ័យក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឱកាសនឹងកើនឡើងសម្រាប់ធានាផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម រួមគ្នានឹងការការពារប្រកបដោយប្រសិទ្ធភាពពីផលប៉ះពាល់មកពីការប្រែប្រួលអាកាសធាតុ។

*ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ប្អូនៗយុវជន យុវនារី ទាំងអស់ជាទីមេត្រី!*

សិក្ខាសាលានេះ បានបញ្ជាក់ឡើងវិញពីភាពងាយរងគ្រោះ និងតួនាទីរបស់យេនឌ័រ ដែលក្នុងនោះមានស្ត្រីកុមារចាស់ជរា ជនពិការ និងជនជាតិភាគតិច។ យើងក៏សង្កេតឃើញការចូលរួមយ៉ាងសកម្មពីយុវជន យុវនារី និងនិស្សិត។ យើងបានយល់ដឹងកាន់តែប្រសើរឡើង ថាការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអភិវឌ្ឍន៍អន្តរវិស័យ និងទាមទារនូវវិធីសាស្ត្រដោះស្រាយ ដែលមានជាលក្ខណៈវិទ្យាសាស្ត្រនិងយុទ្ធសាស្ត្រ ដោយធ្វើសមាហរណកម្មការសម្របសម្រួលនិងមានការចូលរួម ពីគ្រប់ជាន់ថ្នាក់ក្នុងការរៀបចំផែន ការនៅគ្រប់លំដាប់ថ្នាក់។

ឆ្លៀតឱកាសនេះ ខ្ញុំសូមតំណាងក្រសួងស្ថាប័ន ដែលក្រសួងបរិស្ថានបានចាត់លិខិតអញ្ជើញតែងតាំងមន្ត្រីសំខាន់ៗដើម្បីចូលរួមក្នុងក្រុមការងារអន្តរក្រសួង សម្រាប់សម្របសម្រួល SPCR សូមមេត្តាជួយតាមជម្រុញឲ្យ

មានការចាត់តាំងបញ្ជូនមន្ត្រីជាន់ខ្ពស់ និងនាយកគម្រោងវិនិយោគSPCRមកក្រសួងបរិស្ថានឲ្យបានឆាប់តាមការគួរ។ សូមមេត្តាបញ្ជូនយោបល់ និងអនុសាសន៍សម្រាប់ការកែសម្រួលសេចក្តីព្រាងរបាយការណ៍ចាប់ផ្តើម និងផែនការចូលរួមរបស់អ្នកពាក់ព័ន្ធនិងផែនការកសាងសមត្ថភាពបានមុនថ្ងៃ២៥ ធ្នូ ២០១៣។

ជាថ្មីម្តងទៀត ខ្ញុំសូមធ្វើការកោតសសើរយ៉ាងស្មោះចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី យុវជន យុវនារី ក្នុងការចូលរួមគំនិត មតិយោបល់ស្ថាបនាទាំងកំលាំងកាយ ចិត្ត និងប្រាជ្ញា នៅក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។

នៅទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោកលោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ សូមជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។ តាងនាម ឯកឧត្តមបណ្ឌិត **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ខ្ញុំមានកិត្តិយសសូមប្រកាសបិទសិក្ខាសាលាពេលនេះ។

**សូមអរគុណ!**

ឧបសម្ព័ន្ធទី៥៖




ADB
INCEPTION WORKSHOP
ON
MAINSTREAMING CLIMATE RESILIENCE
INTO DEVELOPMENT PLANNING (CDTA 8179-CAM)
4-5 December 2013
Phnom Penh Hotel, Phnom Penh, Cambodia
Organized by: Ministry of Environment and Asian Development Bank
in Cooperation with Line Ministries and Agencies
Hatfield



















# Overview of the Strategic Program for Climate Resilience (SPCR) and Its Technical Assistance

Ancha Srinivasan, Ph.D.
Asian Development Bank

## Pilot Program for Climate Resilience

- Phase I ($1.5 million; 2 Nov 2010 -30 Apr 2013)
  - Mainstreaming of climate resilience in key Ministries
  - Sub-national mainstreaming of climate resilience
  - Strengthening civil society, private sector engagement and gender considerations
  - Science-based adaptation planning
  - Outreach and preparation of Phase Two
- Phase II (**Strategic Program for Climate Resilience**)
  - Original allocation: $50 million grant + $36 million credit (June 2011)
  - New allocation: $5 million grant (Nov. 2012)
  - Co-financing from ADB &others: ~$340 million
  - Duration: Depends on individual projects (2012-2020)

## Key Features of Cambodia's SPCR

- **Prioritization** based on needs and capacities
- Strong **linkages to NAPA** priorities
- Synergies **with disaster risk reduction** efforts
- High potential for **leveraging** MDB funds
- Effective **linkages to Phase I PPCR** activities
- More effective **cross-sectoral coordination**
- Strong **stakeholder engagement & empowerment**
  - **Gender** mainstreaming
  - **Civil society** support mechanism
  - **Private sector** participation
- **Knowledge management** and learning platform
- Benefits to the much larger **Greater Mekong Sub-region**
- Accelerated **poverty reduction** efforts
- Consistency with **PPCR Results Framework**

## SPCR Overview




## SPCR Status at a Glance

- One SPCR technical assistance ($7 million) and 4 SPCR investment projects (one each in water resources, agriculture, transport and urban infrastructure) for $47 million approved by both PPCR subcommittee and the ADB Board
- 3 investment projects – one each in agriculture, transport and urban infrastructure ($32 million) yet to be approved;
- One water resources investment project encountered challenges. The Government decided to reallocate resources to the Rural Roads Improvement Project II;
- PPCR subcommittee is yet to endorse reallocation of resources in revised SPCR.

## SPCR Investment I – Water Resources

**Title:** ***Flood and Drought Management in Pursat province*** (as part of the GMS Flood and Drought Management Project)

Objectives:

- Enhance resilience of irrigation and river bank protection infrastructure
- Strengthen capacity of communities to reduce climate risks
- Promote regional cooperation for climate risk management

**Budget:** **$48 M** (PPCR: $6 M Grant + $4 M Credit) +$35 M (ADB) + $3 M (Govt)

**Status:**

- Project preparation: Completed
- PPCR sub-committee approval: Oct 2012
- ADB Board approval: Dec 2012
- Loan/Grant effectiveness: Not yet effective
- Expected Date of completion: Mar 2019

## SPCR Investment 2 – Agriculture

**Title:** ***Climate proofing of agricultural infrastructure and business-focused Adaptation*** (as part of the Climate Resilient Rice Commercialization Project )

Objectives:

- Enhance demand side water use efficiency (more crop per drop)
- Pilot crop insurance using the weather-based index
- Strengthen climate-resilience of post-harvest infrastructure

**Budget: $64 Million** (PPCR: $5M grant + $5M credit) +$31M (ADB) + $15M (GAFSP) + $8 M (Govt)

**Status:**

- Project preparation: Completed
- PPCR sub-committee approval: Feb 2013
- ADB Board approval: Jun 2013
- Loan/Grant effectiveness: Nov 2013
- Expected Date of completion: Sep 2019

## SPCR Investment 3 – Agriculture

**Title: Climate-resilient agriculture in Koh Kong and Mondulkiri provinces** (*as part of the GMS Biodiversity Conservation Corridors Project*)

Objectives:

- Construct flood protection dikes to reduce salinity and regain rice growing land
- Restore and conserve mangroves to reduce the impacts of sea level rise and coastal flooding
- Improve rainwater harvesting system and enhance resilience of community water supply
- Enhance resilience of small scale agriculture through introduction of drought/ flood tolerant crop varieties and small scale irrigation

**Budget:** $28.4 million (PPCR: $8 M Grant) + $19 M (ADB) + $1.4 (Govt)

**Status:**

- Project preparation: In progress
- Expected PPCR sub-committee approval: Mar 2014
- Expected ADB Board approval: Jun 2014
- Expected Loan/Grant effectiveness: Sep 2014
- Expected Date of completion: Dec 2020

## SPCR Investment 4 – Transport

**Title:** Climate Proofing of Roads in Prey Veng, Svay Rieng, Kampong Chhnang and Kampong Speu Provinces (as part of Provincial Roads Improvement Project)

**Objectives:**

- Improve planning for road infrastructure development (Green planning and Emergency planning)
- Protect transport infrastructure from climate change impacts through improved design standards

**Budget: $79 M** (PPCR: $7 M Grant + $10 M Credit) +$52 M (ADB) + $10 M (Govt)

**Status:**

- Project preparation: Completed
- PPCR sub-committee approval: Nov 2011
- ADB Board approval: Dec 2011
- Loan/Grant effectiveness: Aug 2012
- Expected Date of completion: Sep 2017

## SPCR Investment 5 – Transport

**Title:** ***Climate proofing of rural roads*** (as part of Rural Roads Improvement Project II)

Objectives:

- Provide year-round road connectivity to remote villages
- Strengthen capacity of communities to reduce climate risks
- Enhance climate resilience of rural roads

**Budget: $133.4 M** ($9 M Grant+7 M Credit)+$50 M (ADB)+ $10 M (AusAID)+$40 M (Korea Export-Import Bank) + $5 M Nordic Development Fund + $12.4 (Govt)

**Status:**

- Project preparation: Nearly Completed
- Expected PPCR sub-committee approval: Jan 2014
- Expected ADB Board approval: Mar 2014
- Expected Loan/Grant effectiveness: Oct 2014
- Expected Date of completion: Dec 2019

## SPCR Investment 6 – Water Supply & Sanitation

**Title:** Climate proofing infrastructure in the Southern Economic Corridor (SEC) towns (as part of the GMS Corridor Towns Development Project)

Objectives:

- Mainstream adaptation concerns into urban infrastructure development planning
- Strengthen climate resilience of sanitation systems, including drainage channels, sewerage, sanitary landfills

**Budget: $55 M** (PPCR: $5 M Grant + $5 M Credit) +$ 37 M (ADB) + $7 M (Govt) + $1.5 (Urban Financing Partnership Facility Grant)

**Status:**

- Project preparation: Completed
- PPCR sub-committee approval: Oct 2012
- ADB Board approval: Dec 2012
- Loan/Grant effectiveness: Mar 2013
- Expected Date of completion: Mar 2018

## SPCR Investment 7 – Water Supply & Sanitation

**Title:** Flood-resilient infrastructure development in Kampong Thom and Kampong Chhnang (as part of the Sustainable Urban Development in the Tonle Sap Basin Project)

Objectives:

- Mainstream adaptation concerns into urban infrastructure development planning
- Strengthen climate resilience of river banks, solid waste disposal and other sanitation systems

**Budget: $53 M** (PPCR: $5 M Grant + $5 M Credit) +$37 M (ADB) + $6 M (Govt)

**Status:**

- Project preparation: In Progress
- Expected PPCR sub-committee approval: Apr 2014
- Expected ADB Board approval: June 2014
- Expected Loan/Grant effectiveness: Jan 2015
- Expected Date of completion: Dec 2020

## SPCR Technical Assistance

**Title:** Mainstreaming climate resilience into development planning (MCRDP)
**Outcome:** Sustained institutional and technical capacity in Cambodia to integrate adaptation concerns into development
**Budget:** $7 million + $3-4 million additional financing (Grant)
**Status:**
- PPCR sub-committee approval: Aug 2012
- ADB Board approval: Oct 2012
- Date of Actual Implementation: Sept 2013
- Expected date of completion: Sept 2018

## TA Rationale: Key Challenges for Enhancing Climate Resilience in Cambodia

- Limited information on local impacts
- Low awareness at various levels of governance
- Limited institutional and technical capacities to mainstream adaptation into development planning
- Weak cross-sectoral coordination
- Lack of appropriate adaptation technologies
- Absence of credible disaster response and forecasting mechanisms
- Inadequate funding at various levels

## Focus Areas of TA

| Component | Selected activities | Budget |
|---|---|---|
| SPCR Coordination and Capacity Strengthening | •Coordinating and technical backstopping<br>•Capacity building needs assessment<br>•Training events and workshops<br>•Guidebooks, and reports on sectoral mainstreaming<br>•Technical support for integrating adaptation concerns | $3 Million |
| Civil Society Support Mechanism | •Small grant facility (30-50 grants) to NGOs and CSOs operating in Cambodia to implement adaptation activities<br>•Technical support for mainstreaming adaptation in CSO and NGO operations | $2 Million |
| NAPA Feasibility Support | •NAPA feasibility studies completed for 3 sectors (e.g., water, agriculture and human health)<br>•At least 2 NAPA projects identified for support from international adaptation funds | $1 Million |
| Knowledge Management | •Information from 7 SPCR projects compiled, managed and disseminated<br>•New curriculum for adaptation and DRR developed for secondary and tertiary education<br>•25 new articles on adaptation and DRR published and posted in Cambodian and global web portals | $1 Million |

## Additional Focus Areas Under Consideration ($3-4 million)

- Support to implementation of Cambodia Climate Change Response Strategy Plan in the most vulnerable sectors
- Mainstreaming at Sub-national Level (Ministry of Interior)
- Gender and Climate change adaptation (Ministry of Women Affairs)
- Monitoring and Evaluation of adaptation (Ministry of Planning)

## Key Points for Discussion

1. Does the inception report capture key capacity building needs?
2. How can we strengthen SPCR coordination within the country?
3. Which other high priority issues are critical to achieve the goals of SPCR in Cambodia?
4. What else can be done to strengthen the civil society to implement adaptation and DRR proactively?
5. How can we monitor and evaluate adaptation and DRR investments?

## Thank You!!

ADB

## គម្រោង ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

(ខែកញ្ញា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៨)

ឧបត្ថម្ភដោយ៖ មូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី (TA 8179-CAM)



**ប្រធានបទ៖** សមទ្ធិផល និងមេរៀនសំខាន់ៗ PPCR ដំណាក់កាលទី I, គោលបំណង សិក្ខាសាលា និងលទ្ធផលរំពឹងទុក

**បទបង្ហាញដោយ៖** លោក អ៊ូ ច័ន្ទធារិទ្ធ

**តួនាទី៖** ប្រធានគ្រប់គ្រងគម្រោង **ក្រសួង/ស្ថាប័ន៖** ក្រសួងបរិស្ថាន

Hatfield



## មាតិកា

- សាវតាដើមរបស់ PPCR
- PPCR ដំណាក់កាលទី១
- សមិទ្ធផលរបស់ PPCR ដំណាក់កាលទី១
- មេរៀន និងបទពិសោធន៍ PPCR ដំណាក់កាលទី១
- ទំនាក់ទំនងរវាងគោលបំណង PPCR ដំណាក់កាលទី១ និង PPCR ដំណាក់កាលទី២ ឬ (SPCR)
- ប្រវត្តិសង្ខេបនៃគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍
- សង្ខេបអំពី SPCR នៅកម្ពុជា
- គោលបំណង និងលទ្ធផលរំពឹងទុក
- សេចក្តីសន្និដ្ឋាន



## សាវតារបស់PPCR

- កម្ពុជាក្នុងចំណោមប្រទេសចំនួន៩ ក្នុងតំបន់ទាំងពីរដែលបានចូលរួមក្នុងកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ក្រោមមូលនិធិវិនិយោគអាកាសធាតុ (CIF)

- មូលនិធិវិនិយោគអាកាសធាតុ
  - មូលនិធិបច្ចេកវិទ្យាស្អាតបរិសុទ្ធ
  - មូលនិធិអាកាសធាតុជាយុទ្ធសាស្រ្ត
    - កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ
      - PPCR Phase I: ធ្វើការកំណត់ការងារចាំបាច់សម្រាប់កម្មវិធីយុទ្ធសាស្រ្តភាពធន់នឹងអាកាសធាតុចាំបាច់នៅ កម្ពុជានិងអនុវត្តដោយកម្ពុជាផ្ទាល់ (SPCR)
      - PPCR Phase II: អនុវត្តន៍ជំនួយហិរញ្ញប្បទានបច្ចេកទេសនិងគម្រោងវិនិយោគ SPCR
    - កម្មវិធីបង្កើនថាមពលកកើតឡើងវិញ
    - កម្មវិធីវិនិយោគ ព្រៃឈើ

នៅខែវិច្ឆិការ២០១០ ដល់ខែមេសា ២០១៣ ក្រសួងបរិស្ថានបានសហការជាមួយ គណៈកម្មាធិការជាតិប្រែប្រួលអាកាសធាតុនៅកម្ពុជានិងជាមួយអន្តរក្រសួង អ្នកពាក់ព័ន្ធសំខាន់ៗដែលបានអនុវត្ត PPCR I ដំណាក់កាលទី១



## PPCR ដំណាក់កាលទី១

**ថវិកា: ១.៥ លាន ដុល្លារសហរដ្ឋអាមេរិក ហិរញ្ញប្បទាន**

**គោលបំណង:**

១. បញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងក្រសួង ស្ថាប័នសំខាន់ៗ
២. ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងផែនការថ្នាក់ក្រោមជាតិ
៣. ពង្រឹងការចូលរួមរបស់សង្គមស៊ីវិល វិស័យឯកជន និងយេនឌ័រ
៤. ការធ្វើផែនការបន្សាំផ្អែកលើវិទ្យាសាស្រ្ត
៥. ផ្សព្វផ្សាយ និងរៀបចំ PPCR ដំណាក់កាលទី២

រយៈពេល

- កាលបរិច្ឆេទចាប់ផ្តើម ៣១ មករា ២០១១
- កាលបរិច្ឆេទបញ្ចប់ ៣០ មេសា ២០១៣



## សមិទ្ធផលPPCR ដំណាក់កាលទី១

### សមាសភាព ១ និង ២

- មានធាតុចេញចំនួន ៥ (បំពេញតាមការកំណត់មិនបានពេញទាំងស្រុង)ឯកសារណែនាំនិងឧបករណ៍មួយចំនួនត្រូវបំពេញបន្ថែមនិងទទួលយកដោយក្រសួងស្ថាប័នពាក់ព័ន្ធ។

### សមាសភាព ៣

- *មានធាតុចេញចំនួន ៣* (បំពេញតាមការកំណត់បានគួរពេញចិត្ត) ប៉ុន្តែរបាយការណ៍ស្តីពីវិស័យឯកជនត្រូវការកែសម្រួលខ្លះៗ

### សមាសភាព ៤ និង ៥

- មានធាតុចេញចំនួន ៩ (បំពេញតាមការកំណត់បានគួរពេញចិត្ត)



## ប្រវត្តិសង្ខេបនៃគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

| ១. មូលនិធិគម្រោងPPCR | ជំនួយហិរញ្ញប្បទានឥតសំណង ពីមូលនិធិវិនិយោគអាកាសធាតុ ៖ ៧លាន ដុល្លារអាមេរិក |
|---|---|
| ២. ស្ថាប័នអនុវត្ត | ក្រសួងបរិស្ថាន |
| ៣. រយ:ពេល | ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែកញ្ញា ឆ្នាំ២០១៨ |
| ៦. ធនាគារពាក់ព័ន្ធ | ប្រធានក្រុមការងារ របស់ធនាគារអភិវឌ្ឍន៍អាស៊ី<br>Dr. Ancha Srinivasan<br>Mr. Hem Chanthou<br>Mr. Kob Math |
| ៧. សហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងសាធារណ:ការ និងដឹកជញ្ជូន<br>- ក្រសួងកិច្ចការនារី<br>- គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>- ខេត្តគោលដៅ និងខេត្តពាក់ព័ន្ធ និង<br>- អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន |

## មេរៀន និងបទពិសោធន៍ពី PPCR ដំណាក់កាលទី១

**ការយល់ដឹង ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យមហន្តរាយ និងអាកាសធាតុ**

- ការប្រែប្រួលអាកាសធាតុអាចប៉ះពាល់ធ្ងន់ធ្ងរនិងខូចខាតថវិកាច្រើននៅនាអនាគត
- ភាពធន់និងភាពងាយរងគ្រោះបណ្តាលមកពីការប្រែប្រួលអាកាសធាតុប្រែប្រួលទៅតាមតំបន់នៃប្រទេសកម្ពុជា
- វិស័យគន្លឹះរួមមាន កសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធ ងាយរងគ្រោះយ៉ាងខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ ដែលទាមទាឲ្យមានការបន្សាំខ្ពស់ទៅនឹងការប្រែប្រួលអាកាសធាតុ
- ទាំងពេលបច្ចុប្បន្ននិងអានាគត ហានិភ័យប្រែប្រួលអាកាសធាតុបាននឹងធ្លាក់ទៅលើប្រជាជនងាយរងគ្រោះ អ្នកក្រីក្រ ដោយសារមានសមត្ថភាពនិងធនធានតិចតួចដើម្បីធ្វើការបន្សាំការប្រែប្រួលអាកាសធាតុ ហើយមានលទ្ធភាពតិចតួចណាស់ដើម្បីដោះស្រាយការប៉ះពាល់នេះ។
- ការពង្រឹងព័ត៌មានជលសាស្ត្រឧតុនិយមគឺសម្រាប់កសាងផែនការបន្សាំប្រែប្រួលអាកាសធាតុដ៏ប្រសើរនៅកម្ពុជា។
- ការពង្រឹងព័ត៌មានម៉ូឌែលអំពីអាកាសធាតុគឺចាំបាច់សម្រាប់ការរៀបចំផែនការបន្សាំឲ្យកាន់តែប្រសើរនៅកម្ពុជា។
- ត្រូវកំណត់ចំនុចចាប់ផ្តើមសម្រាប់បញ្ជ្រាបការបន្សាំទៅនឹងអាកាសធាតុ។
- កម្ពុជាកំពុងមានការរីកចំរើនលើផ្នែករៀបចំលិខិតបទដ្ឋានច្បាប់ គោលនយោបាយនិងកម្មវិធីដើម្បីបញ្ជ្រាបនិងទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុ។

www. ppcrcambodia.wordpress.com 7

## មេរៀន និងបទពិសោធន៍ពី PPCR ដំណាក់កាលទី១ (ត)

- ដំណើរការមកដល់ពេលនេះគឺទទួលបានគួរជាទីមោទនៈ ប៉ុន្តែទាំងនេះនៅមិនទាន់គ្រប់គ្រាន់ទេសម្រាប់ការបន្សាំអាកាសធាតុមានប្រសិទ្ធិភាពនិងសមភាពនិងការកាត់បន្ថយហានិភ័យរងគ្រោះ។ កសាងនូវសមត្ថភាពបន្សាំតាមរយៈគោលនយោបាយ និងស្ថានប័នដើម្បីធ្វើឲ្យប្រសើរឡើងនូវដើម្បីគ្រប់គ្រងការប្រែប្រួលអាកាសធាតុឥតខ្ចោះពេលបច្ចុប្បន្ននិងពេលអានាគតគឺជាកាសំខាន់បំផុត។
- ផលប៉ះពាល់អាកាសធាតុគឺជាផលប៉ះពាល់អន្តរវិស័យដែលទាមទាឲ្យមានការឆ្លើយតបរួមគ្នាដែលធ្វើឡើងឆ្លងកាត់ព្រំប្រទល់នៃវិស័យ
- ការធ្វើសមាហរណកម្មកាត់បន្ថយគ្រោះមហន្តរាយនិងអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការនិងកម្មវិធី អភិវឌ្ឍន៦ស្នូល ព្រមទាំងសកម្មភាពកំពុងដំណើរការដទៃទៀតនឹងជួយពង្រឹងការអភិវឌ្ឍដែលធន់បានទៅនឹងអាកាសធាតុ។

www. ppcrcambodia.wordpress.com 8

## ទំនាក់ទំនងរវាងគោលបំណង PPCR ដំណាក់កាលទី១ និង PPCR ដំណាក់កាលទី២

I. បញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងគម្រោងផែនការ គោលនយោបាយថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយពង្រីកការគាំទ្រថវិកាសម្រាប់សកម្មភាពបន្សាំនៅក្នុងវិស័យអភិវឌ្ឍន៍សំខាន់ៗ

II. ពង្រឹងការសម្របសម្រួលនិងការចូលរួមក្នុងចំណោមអ្នកពាក់ព័ន្ធ

III. ធ្វើផែនការបន្សាំផ្អែកលើវិទ្យាសាស្ត្រ

IV. លើកម្ពស់ទំនាក់ទំនងរវាងវិធានការណ៍បន្សាំនិងវិធានការណ៍កាត់បន្ថយហានិភ័យមហន្តរាយ

V. កំណត់នូវកាលានុវត្តភាពគម្រោងវិនិយោគខ្នាតធំព្រមទាំងពង្រឹងសមត្ថភាពដែលអាចជួយគាំទ្រឲ្យមានភាពធន់បានក្នុងប្រទេស។ សកម្មភាពអាទិភាពទាំងនេះនឹងរួមចំណែកឲ្យមានការរីកលូតលាស់នាំឲ្យ កម្ពុជាបន្តផ្លូវអភិវឌ្ឍន៍ដ៏ត្រឹមត្រូវរបស់ខ្លួន បើទោះបីជាមានភាពប្រឈមឮការប្រែប្រួលអាកាសធាតុចេះតែកើនឡើងយ៉ាងណាក្តី។

www. ppcrcambodia.wordpress.com 9

## សង្ខេបអំពី SPCR នៅកម្ពុជា

- អនុម័តដោយ អនុគណកម្មាធិការ PPCR នៅ – ខែមិថុនា ២០១១
- កញ្ចប់ធនធានសរុប( ជាង $៣៩០ លាន )
- ហិរញ្ញប្បទាន PPCR : $៥០ លាន; ឥណទាន PPCR : $៣៦ លាន
- ចូលរួមផ្តល់ថវិកាពី ADB និងប្រភពឯទៀត $២៩៩ លាន
- ជំនួយហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ( ៧លានដុល្លារ )
- គម្រោងវិនិយោគ ចំនួន៧ ( ៤០០លានដុល្លារ )៖
  - គម្រោងធនធានទឹក( ១ )
  - កសិកម្ម( ២ )
  - ហេដ្ឋារចនាសម្ព័ន្ធ( ៤ )

www. ppcrcambodia.wordpress.com 10

## គោលបំណងសិក្ខាសាលា និងលទ្ធផលរំពឹងទុក

| លរ | គោលបំណង | លទ្ធផលរំពឹងទុក |
|---|---|---|
| 1 | • ដើម្បីបង្ហាញជូន និងពិភាក្សាអំពីទិសដៅរួម វិធាន និងវិធីសាស្ត្រ របស់ TA សម្រាប់ធានាការអនុវត្តដោយជោគជ័យ ដើម្បីសម្រេចនូវលទ្ធផលនិងផលសម្រេច និងសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាដូចបានគ្រោងទុក | • ទទួលបានគំនិតមតិ ស៊ីជម្រៅបន្ថែម ទៀតក្នុងការធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្របសម្រួល SPCR និង សម្រាប់បញ្ចប់នូវ របាយការណ៍ចាប់ផ្តើមនេះ ផែនការ អភិវឌ្ឍន៍សមត្ថភាព ផែនការ ព្រមទាំងទទួលបាននូវការឯកភាពគ្នាលើក្របខ័ណ្ឌតាមដានវាយតម្លៃផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ |
| 2 | • ដើម្បីបង្ហាញជូន និងឯកភាពគ្នាលើការស្វែងយល់ ភាពប្រឈម និងសំណើដំណោះស្រាយដែលបានទទួលតាមរយៈការជួបពិភាក្សាជាមួយបណ្តាអ្នកពាក់ព័ន្ធ នឹងការសិក្សាលើឯកសារនានានៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង | • ទទួលបាននូវការមូលមតិលើភាពប្រឈមនិងដំណោះស្រាយ<br>• ព្រមព្រៀងគ្នាលើយន្តការចូលរួមរបស់អ្នកពាក់ព័ន្ធសម្រាប់ការទំនាក់ទំនងមាន<br>• ប្រសិទ្ធិភាពនិងលើកឡើងនូវការផ្សព្វផ្សាយចំណេះដឹងដល់ក្រុមផ្សេងៗដែលពាក់ព័ន្ធ |
| 3 | • ដើម្បីបង្ហាញជូននិងពិភាក្សាលើផែនការសម្រាប់ការ ចូលរួមរបស់អ្នកពាក់ព័ន្ធនិងផ្សព្វផ្សាយនិងទំនាក់ទំនង | • សមាហរណកម្មវិធានការណ៍បន្សាំទៅក្នុងការអភិវឌ្ឍន៍របស់បុគ្គលិកបច្ចេកទេសនិងអ្នកសម្រេចចិត្តនានា |

www. ppcrcambodia.wordpress.com 11

## គោលបំណងសិក្ខាសាលា និងលទ្ធផលរំពឹងទុក (ត)

| លរ | គោលបំណង | លទ្ធផលរំពឹងទុក |
|---|---|---|
| 4 | • បង្ហាញជូននិងពិភាក្សាលើសេចក្តីត្រូវការកសាងសមត្ថភាពការរៀបចំផែនការសកម្មភាពនិងថវិកា និង អនុវត្តសកម្មភាពនានាទាក់ទងទៅនឹងការបន្សាំ និងការ ប្រែប្រួលអាកាសធាតុ | • ឯកភាពគ្នាទៅលើដំណើរការធ្វើការសិក្សាលទ្ធភាពគម្រោង និងបង្កើតជាគម្រោង |
| 5 | • បង្ហាញជូននិងពិភាក្សាលើដំណើការសិក្សាលទ្ធភាពគម្រោង NAPA និងសមត្ថភាពបុគ្គលិករដ្ឋាភិបាលក្នុងការរៀបចំគម្រោងសំណើដាក់ជូនទៅមូលនិធិអន្តរជាតិដូចជាមូលនិធិបន្សាំនិងមូលនិធិអាកាសធាតុបៃតងជាដើម | • សំណើNAPA ដែលមានអាទិភាពខ្ពស់ និងស្វែងរកមធ្យោបាយដើម្បីកំណត់វិធីសាស្ត្ររបស់គម្រោងនិងលទ្ធផលរំពឹងទុករបស់គម្រោងដែលអាចអនុវត្តបាននៅ កន្លែងផ្សេងទៀត |
| 6 | • បង្ហាញជូននិងពិភាក្សាលើការអនុត្តជំហានបន្ទាប់ដើម្បីធ្វើឲ្យប្រសើរឡើង នូវការសម្របសម្រួលចែកចាយនិងផ្លាសប្តូរបទពិសោធន៍ទៅវិញទៅមកក្នុងចំណោមអ្នកពាកព័ន្ធសំខាន់ៗ | • ទទួលលទ្ធផលល្អប្រសើរក្នុងការអនុវត្ត ជំហានបន្តបន្ទាប់ដើម្បីការសម្របសម្រួល ផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹងក្នុងចំណោមអ្នកពាក់ព័ន្ធ<br>សំខាន់ៗ និងមាន ការត្រៀមលក្ខណៈល្អ ដើម្បីអនុវត្ត គម្រោង ធ្វើរបាយការណ៍គម្រោង តាម រយៈចងក្រងរបាយការណ៍រីកចម្រើន បង្កើតគេហទំព័រព័ត៌មានតាមអ៊ីនធឺណេត ចងក្រង និងចែកចាយឯកសារចំណេះដឹង កិច្ចប្រជុំពិគ្រោះយោបល់ វគ្គបណ្តុះបណ្តាលសិក្ខាសាលា ព្រមទាំងប្រព័ន្ធតាមដានវាយតម្លៃ និងដំណើរការផែនការរំកិល។ |

www. ppcrcambodia.wordpress.com 12

# សេចក្តីសន្និដ្ឋាន

- កម្ពុជាបានរីកចំរើនគួរកត់សំគាល់ឆ្ពោះទៅការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពសម្រាប់ការបន្សាំទៅនឹងអាកាសធាតុ ប៉ុន្តែយើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីសម្រេចនូវសមត្ថភាពស្ថាប័ន សម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុឲ្យបានយូរអង្វែង។
- មេរៀនបទពិសោធន៍និងឯកសារចំណេះដឹងពី PPCR I ចាំបាច់យកមកពិចារណានិងប្រើប្រាស់។
- SPCR ( PPCR II ) ស្ថិតនៅក្នុងចំណោមការវិនិយោគអាកាសធាតុដ៏ធំនៅក្នុងអាស៊ី ។
- SPCR ផ្តល់ជូនយើងនូវឱកាសសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ននិងបច្ចេកទេសសម្រាប់បញ្ជ្រាបភាពធន់។
- ការសម្របសម្រួលអន្តរវិស័យ និងការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការកសាងសមត្ថភាព ការប្រើប្រាស់ឧបករណ៍ ចំណេះដឹងគឺជាគន្លឹះសម្រាប់ភាពជោគជ័យ។

www. ppcrcambodia.wordpress.com 13

# សូមអរគុណ!

## លោក អ៊ូ ច័ន្ទជារិទ្ធ

rith_ccd@yahoo.com

www. ppcrcambodia.wordpress.com 14

# គម្រោង ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

(ខែកញ្ញា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៨)

ឧបត្ថម្ភដោយ៖ មូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី (TA 8179-CAM)



ប្រធានបទ៖ សេចក្តីព្រាងរបាយការណ៍ចាប់ផ្តើម និងផែនការការងារ
បទបង្ហាញដោយ៖ លោកបណ្ឌិត ប៊ុច សុខេម
តួនាទី៖ ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹកនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
ក្រុមហ៊ុន៖ ហាតហ្វៀល ខនសាល់ធិន

www. ppcrcambodia.wordpress.com

## មាតិកា:

- គោលបំណង និងវិសាលភាពការងារ
- ការទទួលខុសត្រូវលើការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស (TA)
- របកគំហើញទូទៅ និងសកម្មភាពដំណាក់កាលនៃការចាប់ផ្តើមគម្រោង
- ក្រុមការងារ
- កិច្ចការសង្ខេប និងលទ្ធផលដែលត្រូវសម្រេចបានសម្រាប់គម្រោង TA



## សាវតា៖ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅអាស៊ី

ប្រទេសកម្ពុជាបានសម្រេចថានឹងធ្វើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ កំណត់ការគ្រប់គ្រងបរិស្ថាននៅកម្ពុជា ៖

- គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព
- កាត់បន្ថយផលប៉ះពាល់មកពីការប្រែប្រួលអាកាសធាតុ (កសាងសមត្ថភាពបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងអនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍន៍បៃតង ។ល។)
- ពង្រឹងសមត្ថភាពដើម្បីជម្រុញការបញ្ជ្រាបឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ច្បាប់ និងផែនការនៅថ្នាក់ជាតិ និងក្រោមជាតិ
- ចាត់វិធានការគ្រប់គ្រងការបំពុលបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី។

- ✓ ទឹកជំនន់នៅឆ្នាំ២០១១៖ ប៉ះពាល់ ៣៥៤,២១៧គ្រួសារ(ប្រជាពលរដ្ឋជាង១.៧លាននាក់ក្នុងខេត្តចំនួន១៨)រងផលប៉ះពាល់ និងខូចខាតសេដ្ឋកិច្ច =៥២១លានទៅ៦២៤លានដុល្លារសហរដ្ឋអាមេរិក
- ✓ ព្យុះកេតសាណា ឆ្នាំ២០០៩: ខេត្តចំនួន១៤ក្នុងចំណោម២៤ខេត្ត (ប្រហែលប្រជាពលរដ្ឋ១៨០០០០នាក់)រងផលប៉ះពាល់ និងបាត់បង់សេដ្ឋកិច្ច១៣២លានដុល្លារសហរដ្ឋអាមេរិក
- ✓ ឆ្នាំ២០១២ គ្រោះរាំងស្ងួតប៉ះពាល់សហគមន៍ជាច្រើននៅកម្ពុជា
- ✓ ឆ្នាំ២០១៣ ប្រជាពលរដ្ឋ១.៧លាននាក់រងផលប៉ះពាល់ និងខូចខាតសេដ្ឋកិច្ចប្រមាណ ៨០០លានដុល្លារ




www. ppcrcambodia.wordpress.com

## សាវតា (ត)៖

ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ថ្ងៃទី១ខែវិច្ឆិកាឆ្នាំ២០១៣)និងផែនការយុទ្ធសាស្ត្រតាមវិស័យ ជាគោលនយោបាយ និងផែនការច្បាស់លាស់ សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ស្របនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣- សមត្ថភាពកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដោយពង្រឹងការបន្សាំនិងភាពធន់នឹងអាកាសធាតុ
- SPCR ផ្តោតលើទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍ជនបទ និងទីក្រុង គឺស្របនឹងវិស័យអាទិភាព៤ដែលរដ្ឋាភិបាលកម្ពុជាផ្តោតលើ (ផ្លូវ ទឹក អគ្គិសនី និងប្រជាពលរដ្ឋ)
- SPCR កំពុងចូលរួមចំណែកយ៉ាងសំខាន់ដល់ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ គោលបំណងរបស់យុទ្ធសាស្ត្រចំនួន៥ក្នុងចំណោម៨ទាក់ទងនឹងSPCR (គោលបំណងនៃយុទ្ធសាស្ត្រ១-៣-៥-៧-៨)



www. ppcrcambodia.wordpress.com

## គោលបំណងរបស់គម្រោង៖

- ពង្រឹងសមត្ថភាពស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍
- ផ្តល់ការគាំទ្របច្ចេកទេសដល់ការសម្របសម្រួល និងអនុវត្តគម្រោងវិនិយោគទាំង៧របស់ SPCR ដោយផ្តោតទៅលើវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធ



www. ppcrcambodia.wordpress.com

## សមាសភាគរបស់គម្រោង TA

- **សមាសភាគទី១៖** ពង្រឹងកិច្ចសម្របសម្រួលកម្មវិធី SPCR ការគាំទ្របច្ចេកទេស និងសមត្ថភាពបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍
- **សមាសភាគទី២៖** ធ្វើការសិក្សាគម្រោងលទ្ធភាពលំអិតរបស់គម្រោងមួយចំនួនក្រោម កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ដើម្បីជ្រើសរើសអាទិភាព
- **សមាសភាគទី៣៖** បង្កើតយន្តការគាំទ្រសង្គមស៊ីវិល និងពង្រឹងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងសកម្មភាពការងាររបស់ខ្លួន
- **សមាសភាគទី៤៖** ផលិត និងផ្សព្វផ្សាយឯកសារចំណេះដឹង ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

www. ppcrcambodia.wordpress.com 6

## គោលការណ៍សម្រាប់ការអនុវត្ត ៖

- ផ្អែកលើគោលការណ៍គ្រប់គ្រងបែបបន្សាំ **និងមានសភាពទន់ភ្លន់ព្រមទាំងការសម្របសម្រួលគ្នាដោយមានប្រសិទ្ធភាព។**
- **ការបញ្ជ្រាបយេនឌ័រ** ជាការងារពាក់ព័ន្ធលើគ្រប់វិស័យ និងសកម្មភាពនានារបស់គម្រោង TA
- ក្រុមការងារដែលមានការចាត់តាំងត្រឹមត្រូវ និងដែលផ្តោតជាពិសេសលើការងារជាក្រុម និងការជូនព័ត៌មានគ្នាជាប្រចាំ
- **ឈរលើបទពិសោធន៍ និងមេរៀនពីការអនុវត្ត PPCR ដំណាក់កាលទី១**





## ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស (TA)






## សកម្មភាពដំណាក់កាលនៃការចាប់ផ្តើម (ខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៣)

- សមាជិកក្រុមការងារបានប្រមូលផ្តុំ ការពិភាក្សា និងរៀបចំផែនការអនុវត្តគម្រោង
- ការចុះជួបប្រជុំជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ី
- ការចូលរួមសិក្ខាសាលាជាតិ និងវេទិកាជាតិ និងការពិភាក្សាថ្នាក់តំបន់ជាមួយអង្គការសង្គមស៊ីវិលស្តីពីការគ្រប់គ្រងធនធានទឹក និងការប្រែប្រួលអាកាសធាតុ
- បេសកកម្មដំបូង និងរៀបចំសិក្ខាសាលាចាប់ផ្តើម
- ចុះទស្សនកិច្ចសិក្សាតាមទីកន្លែងនៅខេត្តកំពត កែប និងព្រះសីហនុ សៀមរាប កំពង់ធំ និងពោធិ៍សាត់ ។ល។





## របកគំហើញទូទៅដំណាក់កាលនៃការចាប់ផ្តើម

- **តម្រូវការការកសាងសមត្ថភាព**( ចាប់ផ្តើមដោយវាយតម្លៃពីសេចក្តីត្រូវការ )របស់នាយកដ្ឋានទាំងអស់ក្នុងក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ រួមមានសមត្ថភាពសម្រាប់កំណត់ភាពដែលអាចមានហានិភ័យពីការប្រែប្រួលអាកាសធាតុ និងវិធានការសម្រាប់ដោះស្រាយផលប៉ះពាល់
- **ការសម្របសម្រួល**ត្រូវតែប្រសើរឡើងជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុក្នុងក្រសួងបរិស្ថាន និងរវាងក្រសួងបរិស្ថាន ជាមួយកម្មវិធី SPCR និងក្រសួងពាក់ព័ន្ធ
- **គេហទំព័រ** TA នឹងត្រូវបានសម្របសម្រួលតាមរយៈក្រសួងបរិស្ថាន និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ
- **ផែនការយុទ្ធសាស្ត្រ**ជាតិ និងផែនការយុទ្ធសាស្ត្រតាមវិស័យឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ផ្តល់នូវព័ត៌មានដើមគ្រាសំខាន់ៗដែលអាចប្រើសម្រាប់ការអនុវត្ត TA
- តម្រូវការចាំបាច់ដើម្បី**ដាក់បញ្ចូល** និងធ្វើការជាមួយបណ្តាញ និងគម្រោងប្រែប្រួលអាកាសធាតុនានា ( ឧ.កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា សហភាពអឺរ៉ុប និង UNDP ជាដើម ) និងសង្គមស៊ីវិល។



## របកគំហើញទូទៅដំណាក់កាលនៃការចាប់ផ្តើម (ត)

- ត្រូវ**បង្កើនការយល់ដឹង និងចំណេះដឹង**ស្តីពីការបន្សាំ ភាពធន់ និងភាពងាយរងគ្រោះ ពិសេសក្នុងចំណោមក្រុមដែលងាយរងគ្រោះ និងប្រព័ន្ធផ្សព្វផ្សាយ
- ត្រូវយកចិត្តទុកដាក់ជាពិសេសដើម្បីធានា**ការបញ្ជ្រាបយេនឌ័រ**អោយកាន់តែមានប្រសិទ្ធភាពក្នុងដំណើរការអនុវត្តសកម្មភាពគម្រោង លទ្ធផល និងការសម្រេចចិត្ត
- ត្រូវ**ពង្រឹងបណ្តាញដែលមានស្រាប់** រួមមានបណ្តាញពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ និងធនធានទឹក
- ត្រូវការសកម្មភាពកសាងសមត្ថភាពដើម្បីអោយមន្ត្រីរាជការមានជំនាញក្នុងការសរសេរសំណើ និង**ការសិក្សាពីលទ្ធភាពលំអិតសម្រាប់គម្រោងមួយចំនួនក្រោមកម្មវិធី NAPA ឬ ផែនការសកម្មភាពជាតិ NAPs ដើម្បីគៀងគរថវិកាសម្រាប់ការអនុវត្ត**
- ត្រូវបង្កើតសូចនាករ**តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ គម្រោង** ដើម្បីដាក់បញ្ចូលក្នុងសំណើ



## របកគំហើញទូទៅនៃដំណាក់កាលការចាប់ផ្តើម (ត)

- ពង្រឹងការយល់ដឹងពីភាព**ងាយរងគ្រោះ និងការបន្សាំ** (រួមបញ្ចូលរបៀបនៃការវាយតម្លៃ )ក្នុងចំណោមរដ្ឋាភិបាល និងសហគមន៍
- **ការវាយតម្លៃភាពងាយរងគ្រោះជាប្រព័ន្ធ**ត្រូវបានស្នើឡើង រួមបញ្ចូលជីវចម្រុះសរីរាង្គ សេដ្ឋកិច្ចសង្គម និងកត្តានយោបាយ) សម្រាប់ធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ
- ត្រូវការចាំបាច់នូវ**ទិន្នន័យដើមគ្រាបន្ថែមទៀត** ក្នុងផ្នែកត្រួតពិនិត្យហានិភ័យអាកាសធាតុ ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការវិភាគសេដ្ឋកិច្ចសម្រាប់គម្រោងNAPA និងគោលការណ៍ណែនាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់
- ត្រូវពង្រឹង**បណ្តាញជលសាស្ត្រឧតុនិយមវិទ្យា ។**

## ក្រុមការងារ (អន្តរជាតិ)

| ឈ្មោះ | តួនាទី | ថ្ងៃខែចាប់ផ្តើមការងារ |
|---|---|---|
| បណ្ឌិត ប៊ិច សុខេម | ប្រធានក្រុម និងជាអ្នកជំនាញផ្នែកធនធានទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ |
| លោក តូម៉ាស ប៉ាវិន | អ្នកជំនាញការអន្តរជាតិគ្រប់គ្រងចំណេះដឹង និងទំនាក់ទំនង | ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ |
| លោក ភិទ័រ ម៉ាកណានី | អ្នកជំនាញការអន្តរជាតិលើការងារគម្រោង NAPA | ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ |
| កញ្ញា ប៉ូឡា ស៊ីលវ៉ា វិលយានូអេវ៉ា | អ្នកជំនាញការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៣ |
| បណ្ឌិត ហាមុត គ្រូម៉ាន់ | អ្នកជំនាញការអន្តរជាតិ ផ្នែកកសិកម្ម និងការប្រែប្រួលអាកាសធាតុ | ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ |
| បណ្ឌិត ស្កត កាន់លីហ្វ | អ្នកជំនាញការអន្តរជាតិ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ | ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ |



## ក្រុមការងារ (ជាតិ)

| ឈ្មោះ | តួនាទី | ថ្ងៃខែចាប់ផ្តើមការងារ |
|---|---|---|
| បណ្ឌិត ដោក ដូម៉ា | អនុប្រធាន អ្នកជំនាញគ្រប់គ្រង SPCR | ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ (ពេញម៉ោង) |
| លោក សួន សេង | អ្នកជំនាញត្រួតពិនិត្យ តាមដាន និងវាយតម្លៃ | ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ |
| លោក វ៉ាន់ សុខជា | អ្នកជំនាញព័ត៌មាន និងផ្សព្វផ្សាយ | ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ |
| លោកស្រី យូ ប៉ោនី | អ្នកជំនាញគ្រប់គ្រងចំណេះដឹង និងទំនាក់ទំនង | ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ (ពេញម៉ោងចាប់ពីថ្ងៃទី០១ ខែតុលាឆ្នាំ២០១៣) |
| កញ្ញា ទូស សោភ័ណ | អ្នកជំនាញការងារបញ្ជ្រាបយេនឌ័រ | ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ |
| លោក ហាក់ យូ | អ្នកជំនាញហេដ្ឋារចនាសម្ព័ន្ធ និងអាកាសធាតុ | ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ (ពេញម៉ោង) |
| លោក ហេង ប៊ូវ៉ាន់ | អ្នកជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ | ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ |
| បណ្ឌិត ឡាយ ចន្ទី | អ្នកជំនាញការងារគម្រោង NAPA | ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ |
| បណ្ឌិត ចែម ផល្លា | អ្នកជំនាញការងារគម្រោង NAPA | ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ |
| | អ្នកជំនាញកសិកម្ម ធនធានទឹក និងការប្រែប្រួលអាកាសធាតុ | កំពុងជ្រើសរើសអ្នកជំនួស (ការងារពេញម៉ោង) |



## បញ្ជីឯកសារចំណេះដឹងរបស់គម្រោង TA

| ឯកសារចំណេះដឹងដែល TA នឹងផលិត | កាលបរិច្ឆេទ |
|---|---|
| របាយការណ៍ស្តីពីការណែនាំសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ | ខែមីនា ឆ្នាំ២០១៤ |
| របាយការណ៍ស្តីពីការណែនាំសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ | ខែកញ្ញា ឆ្នាំ២០១៤ |
| របាយការណ៍ស្តីពីឧបករណ៍កំណត់ហានិភ័យនៃការប្រែប្រួលអាកាសធាតុដែលអាចប្រើក្នុងលក្ខខណ្ឌបរិបទប្រទេសកម្ពុជា | ខែកញ្ញា ឆ្នាំ២០១៤ |
| របាយការណ៍ស្តីពីការណែនាំសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍កសិកម្ម | ខែមីនា ឆ្នាំ២០១៥ |
